បទដ្ឋានសកល
សម្រាប់គណនេយ្យភាព
អង្គការសង្គមស៊ីវិល

# ១២
# គោលការណ៍អនុវត្ត
# ដើម្បីមានគណនេយ្យភាពរឹងមាំ

## ឯកសារណែនាំ

# ចូលរួម
# ជាមួយគ្នាដើម្បី
# លើកកម្ពស់
# គណនេយ្យភាពឱ្យ
# កាន់តែរឹងមាំ

# មាតិកា

ហេតុអ្វីបានជាចាំបាច់មានឯកសារណែនាំនេះ? ៤
រចនាសម្ព័ន្ធ ៦

**ជំពូកទី១: អ្វីដែលយើងចង់សម្រេចបាន**
គោលការណ៍អនុវត្តទី១: យុត្តិធម៌ និងសមភាព ៨
គោលការណ៍អនុវត្តទី២: សិទ្ធិស្ត្រី និងសមភាពយេនឌ័រ ១២
គោលការណ៍អនុវត្តទី៣: សុខុមាលភាពភពផែនដី ១៦
គោលការណ៍អនុវត្តទី៤: ការផ្លាស់ប្តូរវិជ្ជមានជាប់លាប់ ២០

**ជំពូកទី២: អភិក្រមដើម្បីផ្លាស់ប្តូរ**
គោលការណ៍អនុវត្តទី៥: ការងារនាំមុខដោយប្រជាជន ២៤
គោលការណ៍អនុវត្តទី៦: ភាពជាដៃគូរឹងមាំ ២៨
គោលការណ៍អនុវត្តទី៧: ឥស្សរមតិដើម្បីការផ្លាស់ប្តូរជាមូលដ្ឋាន ៣២
គោលការណ៍អនុវត្តទី៨: អង្គការបើកចំហរ ៣៦

**ជំពូកទី៣: អ្វីដែលយើងត្រូវពង្រឹងបន្ថែមក្នុងអង្គការ**
គោលការណ៍អនុវត្តទី៩: បុគ្គលិកនិងអ្នកធ្វើការស្ម័គ្រចិត្តប្រកបដោយ ភាពអង់អាចនិងប្រសិទ្ធភាព ៤០
គោលការណ៍អនុវត្តទី១០: ធនធានចាត់ចែងបានល្អ ៤៤
គោលការណ៍អនុវត្តទី១១: ការធ្វើសេចក្តីសម្រេចចិត្តបែបឆ្លើយតប ៤៨
គោលការណ៍អនុវត្តទី១២: គណៈដឹកនាំមានការទទួលខុសត្រូវ ៥២

ពាក្យគន្លឹះ និងនិយមន័យ ៥៥

# ហេតុអ្វីបានជាចាំបាច់មានឯកសារណែនាំនេះ?



បទដ្ឋានសកលដើម្បីគណនេយ្យភាពអង្គការសង្គមស៊ីវិល ត្រូវបានចងក្រងឡើងដោយមានការចូលរួមពីដៃគូពាក់ព័ន្ធចំនួន ៩ ដែលមានបទពិសោធន៍ជ្រាលជ្រៅ ធ្វើការលើកកម្ពស់គណនេយ្យភាពអង្គការសង្គមស៊ីវិលទូទាំងសកលលោក។[១] ដោយកសាងលើបទពិសោធន៍ដែមានស្រាប់ ជាក់ស្តែងរបស់ពួកគេ និងដោយរួមគ្នាជាមួយដៃគូពិគ្រោះយោបល់ផ្សេងៗជាច្រើនទៀត ពួកគេបានបង្កើតឡើងនូវក្របខ័ណ្ឌគណនេយ្យភាពរួមមួយសម្រាប់អង្គការសង្គមស៊ីវិល (CSOs) ដែលផ្តោតការយកចិត្តទុកដាក់លើកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធជាចំនុចអាទិភាពនៅក្នុងការអនុវត្តការងាររបស់ពួកគេ។

**ឯកសារណែនាំនេះ បំពេញបន្ថែមលើបទដ្ឋានសកល និងផ្តល់ឱវាទជាក់ស្តែងអំពីរបៀបប្រើប្រាស់បទដ្ឋានសកលទៅដល់ភាគីពាក់ព័ន្ធផ្សេងៗ ដូចជា អ្នកចង់មានគំនិតផ្តួចផ្តើមបង្កើតគណនេយ្យភាពអង្គការសង្គមស៊ីវិល អង្គការសង្គមស៊ីវិល អ្នកធ្វើគោលនយោបាយ និងស្ថាប័នផ្តល់មូលនិធិ។**

ដោយពន្យល់កាន់តែច្បាស់ថែមទៀត នូវគោលការណ៍អនុវត្តទាំង ១២ និងសកម្មភាពគន្លឹះពាក់ព័ន្ធរបស់វា ឯកសារនេះពន្យល់នូវជំហាននានាសម្រាប់អនុវត្តជាសកល ដែលនៅក្នុងនោះ អង្គការសង្គមស៊ីវិលពិតជាត្រូវមានគណនេយ្យភាពចំពោះភាគីពាក់ព័ន្ធ ចំពោះប្រសិទ្ធិភាពការងារ អភិក្រម និងដំណើរការអង្គការ។

សេចក្តីពន្យល់ទាំងឡាយនៅក្នុងសេចក្តីណែនាំនេះខុសប្លែកបន្តិចទៅនឹងទម្រង់លក្ខណៈបទដ្ឋានសកលដែលជាបទដ្ឋានយោងពឹងផ្អែកលើការស្ម័គ្រចិត្ត ដែលតម្រូវឱ្យអ្នកប្រើប្រាស់នីមួយៗសម្របទៅតាមលក្ខណៈផ្ទាល់ខ្លួន សមត្ថភាពស្ថាប័ន និងបរិបទវប្បធម៌។ សេចក្តីណែនាំនេះផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធ និងប្រើប្រាស់ប្រព័ន្ធរិះគន់ស្ថាបនា ដែលនេះ ជាកិច្ចការនៅពីក្រោយការប្រមូលគំនិតយោបល់ទស្សនៈ និងតម្រូវការ។ ជំនួសមកវិញ វាពិចារណាតម្រូវការរបស់ស្ថាប័ន ដែលត្រូវវិភាគព័ត៌មានដែលបានប្រមូលពិភាក្សាលើមតិរិះគន់ និងធ្វើការកែសម្រួល។ ដោយផ្តល់សេចក្តីណែនាំលើរបៀបបិទបញ្ចប់មតិរិះគន់ សៀវភៅសេចក្តីណែនាំ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់អនុវត្តនូវខ្លឹមសារដែលបានចែងក្នុងបទដ្ឋានសកល និងសម្រាប់ដៃគូរបស់ខ្លួនយល់ថាជាការជំរុញឱ្យកាន់តែមានគណនេយ្យភាពរឹងមាំ។

---

១ ដៃគូរគម្រោងទាំងប្រាំបួន រួមមានអង្គការ Accountable Now, the Australian Council for International Development (ACFID), the Balkan Civil Society Development Network (BCSDN), the Cooperation Committee for Cambodia (CCC), InterAction, the NGO Quality Assurance Certification Mechanism (QuAM), Rendir Cuentas, Viwango, និង the Voluntary Action Network India (VANI)។ អង្គការទាំងនេះ ត្រូវបានគាំទ្រដោយមជ្ឈមណ្ឌលសង្គមស៊ីវិលអន្តរជាតិ (International Civil Society Centre) ជាដៃគូអនុវត្តមួយ ដោយមានការគាំទ្រមូលនិធិពីទីភ្នាក់ងារស៊ុយអែដដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (Sida)។



## ផ្តល់ការណែនាំដល់ជនគ្រប់រូបដែលមានបំណង៖

- រៀនសូត្រពី និង កែលម្អការសន្ទនាជាមួយភាគីពាក់ព័ន្ធ និងដៃគូ
- កំណត់នូវទម្រង់ជាគំរូមួយ សូចនាករ និងបន្ទាត់មូលដ្ឋាន ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាព
- តាក់តែងនូវការធ្វើប្រជាមតិ កម្រងសំណួរ និងយន្តការដើម្បីវាស់វែងវឌ្ឍនភាព
- បង្កើតប្រព័ន្ធនានាសម្រាប់ត្រួតពិនិត្យខ្លួនឯង និងការផ្ទៀងផ្ទាត់ ដូចជាស្វ័យវង្វាយតម្លៃ ការវាយតម្លៃដោយមិត្ត ឬ ប្រព័ន្ធសម្រាប់ផ្តល់វិញ្ញាបនបត្រ
- រៀបចំនិងកែលម្អគម្រោង គោលនយោបាយ យុទ្ធសាស្ត្រ និង សកម្មភាព
- សម្របបទដ្ឋាន និងក្រមរបស់ពួកគេផ្ទាល់ទៅនឹងបទដ្ឋានសកល
- អភិវឌ្ឍក្របខ័ណ្ឌ និងឧបករណ៍កសាងសមត្ថភាព និងផ្តល់ការគាំទ្រមានគោលដៅជាក់លាក់ ដោយផ្អែកលើសេចក្តីត្រូវការរបស់អង្គការ
- សម្របសម្រួលកិច្ចពិភាក្សាស្តីពីកិច្ចគាំពារបរិយាកាសអំណោយផល
- កែលម្អការយល់ដឹងរបស់ពួកគេអំពីការងាររបស់អង្គការសង្គមស៊ីវិល តួនាទីនិងការទទួលខុសត្រូវរបស់ពួកគេ
- តម្រូវឱ្យអង្គការសង្គមស៊ីវិលមានគណនេយ្យភាព

# រចនាសម្ព័ន្ធ

សៀវភៅណែនាំនេះ ចែកចេញជា ៣ជំពូក និងគោលការណ៍អនុវត្តចំនួន១២។ សម្រាប់គោលការណ៍អនុវត្តនីមួយៗ មានសេចក្ដីពន្យល់អំពីសារសំខាន់ និងសារតាសម្រាប់សកម្មភាពអង្គការសង្គមស៊ីវិល និងរបៀបសម្រេចឱ្យបាននូវគោលការណ៍អនុវត្តនីមួយៗ ដែលទាំងនេះនឹងរួមវិភាគទានជួយឱ្យមានគណនេយ្យភាពកាន់តែរឹងមាំ និងការផ្លាស់ប្ដូរជាវិជ្ជមាន។ គោលការណ៍អនុវត្តនីមួយៗអមទៅដោយសកម្មភាពជាគន្លឹះសំខាន់ៗដែលចង្អុលបង្ហាញថា សង្គមស៊ីវិលកំពុងតែឆ្លើយតបទៅនឹងគោលការណ៍អនុវត្ត។



**សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត** ជួយថែមទៀតដើម្បីត្រួតពិនិត្យវឌ្ឍនភាពរបស់អង្គការសង្គមស៊ីវិល សំដៅអនុវត្តបទដ្ឋានសកល។ សូចនាករទាំងនេះបង្ហាញនៅក្នុងបញ្ជីមួយ ដែលភ្ជាប់ជាមួយនឹងគោលការណ៍អនុវត្ត និងភ្ជាប់ជាមួយនឹង រង្វាស់បែបគុណភាពដែលអាចវាស់វែងបាន ដើម្បីបង្ហាញ នូវវឌ្ឍនភាព ឬចង្អុលបង្ហាញពីការដើរថយក្រោយ។ អ្នកប្រើអាចប្រើវាក្នុងទម្រង់ដើម កែសម្រួលវាតាមសេចក្ដីត្រូវការជាក់លាក់របស់ពួកគេ ឬ ប្រើវាជាការណែនាំដើម្បីបង្កើតសូចនាករអាចវាស់បានថ្មីកាន់តែជាក់លាក់។ សូចនាករវឌ្ឍនភាព សួររកភស្តុតាងពីរប្រភេទ៖

**កិច្ចដំណើរការគោលនយោបាយ និងរចនាសម្ព័ន្ធ** បង្ហាញពីការផ្លាស់ប្ដូរ និងផលប៉ះពាល់ផ្ទៃក្នុង ក្នុងអង្គការដែលអាចធ្វើឱ្យអង្គការសង្គមស៊ីវិលអនុវត្តសកម្មភាពសំខាន់ៗ។

**មតិកែលម្អរបស់ភាគីពាក់ព័ន្ធ** ចង្អុលបង្ហាញថាផលប៉ះពាល់ ដែលគួរឱ្យជឿជាក់បាននោះ គឺសកម្មភាពជាច្រើនរបស់អង្គការសង្គមស៊ីវិលមានទៅលើភាគីពាក់ព័ន្ធ និងជីវិតរបស់ពួកគេ។ ភស្តុតាងទាំងពីរប្រភេទ មានលក្ខណៈសំខាន់ស្មើគ្នា នៅក្នុងការវាស់វែងផលប៉ះពាល់ ហើយខ្លឹមសារដែលបានពន្យល់ អនុញ្ញាតឱ្យមានការបត់បែនទៅតាមអង្គការនីមួយៗ នៅក្នុងរបៀបដែលពួកគេចង់បង្ហាញវឌ្ឍនភាពទាក់ទិននឹងបរិបទ គោលដៅ និងសមត្ថភាពរៀងៗខ្លួនរបស់ពួកគេ។ ប្រសើរបំផុត ជានិច្ចកាល អង្គការសង្គមស៊ីវិលគប្បីពិនិត្យពិច័យភស្តុតាងដែលទទួលបានពីប្រភពផ្លូវការ ជាមួយនឹងព័ត៌មានជាទស្សនដែលទទួលបានតាមរយៈមតិកែលម្អ។ ប្រការនេះធានាឱ្យបានប្រាកដថា ពួកគេអាចបកស្រាយយ៉ាងត្រឹមត្រូវនូវព័ត៌មានដែលទទួលបាន និងកំណត់បានថាការងាររបស់ពួកគេពិតជាផលិតបាននូវលទ្ធផលដែលចង់បានមែន។

**សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំងនិងសកម្មភាព** ឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្តនីមួយៗ បំពេញបន្ថែមលើសូចនាករវឌ្ឍនភាពដែលអាចមាន។ សំណួរនិងសកម្មភាពទាំងនេះ លើកទឹកចិត្តឱ្យមានការឆ្លុះបញ្ចាំង និងការសន្ទនាកាន់តែស៊ីជម្រៅ នៅក្នុងអង្គការ ក៏ដូចជាជាមួយភាគីពាក់ព័ន្ធដទៃទៀត ជាពិសេស អំពីបញ្ហាប្រឈមនានាក្នុងការអនុវត្ត។ លើសពីនេះ សំណួរណែនាំអាចជំរុញការអភិវឌ្ឍ និងការបង្កើតសំណួរតាមដាន និងវាយតម្លៃ ដែលអាចប្រើបាននៅពេលក្រោយ ដើម្បីប្រមូលមតិកែលម្អ និងធាតុចូល ។

សូចនាករ មធ្យោបាយនៃការផ្ទៀងផ្ទាត់ សំណួរណែនាំ និងឧទាហរណ៍ទាំងអស់ គឺជាគំនិតផ្ដល់ជូនអ្នកប្រើ ដែលអាចជ្រើសរើស និងកែសម្រួលយោងតាមរិបទក្នុងស្រុក និងបរិបទវប្បធម៌របស់ពួកគេ ប្រភេទអង្គការរបស់ពួកគេ ឬ កម្រិតចង់បាន និងផលប៉ះពាល់ខ្លាំងដែលពួកគេចង់តាមដាន ឬ វាយតម្លៃ។

**ពាក្យគន្លឹះ និងនិយមន័យ** ដែលត្រូវបានប្រើក្នុងបទដ្ឋានសកល និងសៀវភៅណែនាំ ត្រូវបានដាក់បញ្ចូលនៅក្នុងសទ្ទានុក្រមមួយនៃខាងចុងបញ្ចប់នៃឯកសារនេះ។

---

## សូមផ្ញើឱ្យពួកយើងនូវមតិកែលម្អរបស់អ្នក

យើងខ្ញុំចង់ដឹងអំពីចំណុចណានៃឯកសារណែនាំនេះដែលមានប្រយោជន៍ និងចំណុចណាដែលអាចកែលម្អបន្ថែមទៀត។ ហេតុដូច្នេះ យើងខ្ញុំសូមឱ្យអ្នកផ្ដល់យោបល់ មតិកែលម្អ និងសំណួរទៅកាន់ feedback@csostandard.org។ ដើម្បីព័ត៌មានបន្ថែម ដូចជាធនធាន និងឯកសារពាក់ព័ន្ធកំពុងរៀបចំ សូមមើល www.csostandard.org

---

# ជំពូកទី១ / អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី១




### យុត្តិធម៌ និងសមភាព

**យើងនឹងដោះស្រាយអំពើអយុត្តិធម៌ ការផាត់ចោល វិសមភាព ភាពក្រីក្រ និងហិង្សា ដើម្បីបង្កើតសុខុមាលភាពសង្គមសម្រាប់ទាំងអស់គ្នា។**

---

នៅក្នុងសង្គមមានយុត្តិធម៌ និងសមភាពមួយ មនុស្សគ្រប់រូបអាចមានសិទ្ធិ និងសេរីភាពដូចគ្នា ក្នុងការធ្វើការជ្រើសរើសអំពីបែបបទជីវិតរបស់ពួកគេ ដោយមិនគិតពីសញ្ជាតិ ទីកន្លែង ភេទ អត្តសញ្ញាណយេនឌ័រ អាយុ ដើមកំណើត ជាតិពន្ធុ អន្តោគ្រាមភាព សាសនា លទ្ធភាព វណ្ណៈ ស្ថានភាពសង្គមសេដ្ឋកិច្ច ឬ ស្ថានភាពដទៃទៀតរបស់ពួកគេឡើយ។ យុត្តិធម៌ និងសមភាព អនុញ្ញាតឱ្យប្រជាជនចូលរួមក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ជីវិតពួកគេ និង តម្រូវឱ្យអ្នកមានអំណាចមានគណនេយ្យភាព។ ខណៈដែលតួអង្គពលរដ្ឋស្វែងរកការផ្លាស់ប្ដូររួមជាមួយប្រជាជន អង្គការសង្គមស៊ីវិលត្រូវតែធ្វើការយ៉ាងសកម្ម ឆ្ពោះទៅកាន់សង្គមបែបបរិយាប័នមួយ និងព្យាយាមជះឥទ្ធិពលលើ ឥរិយាបថ វប្បធម៌ និងប្រព័ន្ធនានា ដើម្បីធានាឱ្យបានប្រាកដថាប្រជាជនទាំងអស់ ជាពិសេសប្រជាពលរដ្ឋងាយរងគ្រោះ និងជួបការលំបាកបំផុត ទទួលបាននូវយុត្តិធម៌ និងស្មើភាព។

### សកម្មភាពគន្លឹះ

១.១
ស្ដាប់ប្រជាជន ស្វែងយល់ និងដោះស្រាយមូលហេតុជាឫសគល់ និងផលប៉ះពាល់នៃអយុត្តិធម៌ ហិង្សា និងវិសមភាព។

១.២
ដឹកនាំដោយធ្វើជាគំរូ: ប្រកាន់ខ្ជាប់បរិយាប័ន គោរព និងជំរុញសិទ្ធិមនុស្ស នៅក្នុងអង្គការរបស់យើង និងធានាឱ្យបានប្រាកដថាយើងមិនធ្វើឱ្យមានអន្តរាយដល់ខ្លួនយើង។

១.៣
គាំទ្រប្រជាជនឱ្យដឹងពីសិទ្ធិរបស់ពួកគេ និងតម្រូវឱ្យមានគណនេយ្យភាពចំពោះអ្នកទាំងឡាយដែលទទួលខុសត្រូវលើការគោរព ការការពារ និងការបំពេញសិទ្ធិ។

១.៤
សហការជាមួយតួអង្គដទៃទៀតដើម្បីដោះស្រាយជាសមូហភាពនូវមូលហេតុជាឫសគល់ និងផលប៉ះពាល់នៃអយុត្តិធម៌ ហិង្សា និងវិសមភាព និងដើម្បីធានាឱ្យបានប្រាកដថាសិទ្ធិរបស់ប្រជាជនទាំងអស់ត្រូវបានគេគោរព និងការពារ។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជាការសិក្សាវាយតម្លៃការរៀបចំផែនការ របាយការណ៍តាមដាននិងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល ធ្វើការវិភាគបរិបទ និងវិវាទដោយមានការចូលរួមនិងជាប្រព័ន្ធយ៉ាងទៀងទាត់ និងពិភាក្សា និងធ្វើការផ្លាស់ប្តូរចាំបាច់នានា រួមជាមួយភាគីពាក់ព័ន្ធរបស់ខ្លួន។
- ការរៀបចំកម្មវិធី និងអន្តរាគមន៍ប្រភេទផ្សេងៗនៃអង្គការសង្គមស៊ីវិល គឺផ្អែកលើសេចក្តីត្រូវការជាក់ស្តែង និងអាទិភាពនានាដែលកំណត់ដោយប្រជាជនទាំងឡាយដែលខ្លួនសំដៅគាំទ្រ ឬ ជួយការពារ។
- ការងាររបស់អង្គការសង្គមស៊ីវិល មានផលប៉ះពាល់ផ្ទាល់លើការសម្រេចបានយុត្តិធម៌ សន្តិភាព និងសិទ្ធិស្មើគ្នា សម្រាប់ទាំងអស់គ្នា។
- អង្គការសង្គមស៊ីវិល កំណត់អត្តសញ្ញាណ និងវាយតម្លៃយ៉ាងទៀងទាត់ នូវហានិភ័យទាំងឡាយដែលភាគីពាក់ព័ន្ធប្រឈម ទាក់ទិននឹងការរើសអើង ហិង្សា ការបំពាន ការកេងប្រវ័ញ្ច ឬប្រមាថ និងអភិវឌ្ឍយុទ្ធសាស្ត្រនានាដើម្បីទប់ស្កាត់ ឬ កាត់បន្ថយចំណុចទាំងនេះ។ អង្គការសង្គមស៊ីវិល ខិតខំធ្វើអ្វីៗទាំងអស់ដែលខ្លួនអាចធ្វើបាន ដើម្បីជៀសវាងការធ្វើឱ្យប្រជាជនជួបប្រទះអន្តរាយថែមទៀត។
- អង្គការសង្គមស៊ីវិល សហការជាមួយភាគីពាក់ព័ន្ធផ្សេងៗ នៅក្នុងការជំរុញយុត្តិធម៌ និងសិទ្ធិស្មើគ្នា សម្រាប់ទាំងអស់គ្នា។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជាអង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬប្រភពដែលអាចមានដទៃទៀតបង្ហាញថា៖

- ភាគីពាក់ព័ន្ធ យល់ថាកម្មវិធីរបស់អង្គការសង្គមស៊ីវិលយល់ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់លាក់ មូលហេតុជាឫសគល់នៃបញ្ហា និងវប្បធម៌របស់ពួកគេ។
- ភាគីពាក់ព័ន្ធ យល់ថាអង្គការសង្គមស៊ីវិលមានលក្ខណៈបរិយាប័ន និង មិនធ្វើឱ្យមានអន្តរាយ។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងព័ត៌មាន និងកាលានុវត្តភាព ដើម្បីសំដែងនូវសិទ្ធិរបស់ពួកគេ ទៅកាន់អ្នកទទួលខុសត្រូវបំពេញកិច្ច។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងរបៀបដែលអង្គការសង្គមស៊ីវិល ឆ្លើយតបទៅនឹងមតិកែលម្អរបស់ពួកគេ និងកាលានុវត្តភាពមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្តរបស់អង្គការ។
- ភាគីពាក់ព័ន្ធ យល់ថាអង្គការសង្គមស៊ីវិលធ្វើការជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីមានផលប៉ះពាល់ប្រកបដោយអត្ថន័យលើមូលហេតុ ផ្នែកស្ថាប័ន និងវប្បធម៌នៃភាពក្រីក្រ ការផាត់ចោល ហិង្សា អយុត្តិធម៌ និងវិសមភាព។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកបានធ្វើការផ្ទៀងផ្ទាត់ និងវិភាគព័ត៌មានអំពី មូលហេតុជាឫសគល់នៃភាពក្រីក្រ ការផាត់ចោល ហិង្សា អយុត្តិធម៌ និងវិសមភាព យ៉ាងដូចម្តេច?
- តើអ្វីទៅគឺជាផលប៉ះពាល់នៃវត្តមាន និងសកម្មភាពរបស់អ្នក លើក្រុមផ្សេងៗ និងតើអ្នកធ្វើអ្វីខ្លះដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមាន?
- តើអ្នកប្រាប់ប្រជាជនអំពីសិទ្ធិរបស់ពួកគេ និងពីអ្នកណាដែលត្រូវទាមទារសិទ្ធិទាំងនោះ រួមទាំងនៅក្នុងអង្គការរបស់អ្នក យ៉ាងដូចម្តេច? តើអ្នកគាំទ្រពួកគេ នៅក្នុងការជំរុញសិទ្ធិទាំងនេះ យ៉ាងដូចម្តេច?
- តើអ្នកធានាឱ្យបានប្រាកដយ៉ាងដូចម្តេចថាការងាររបស់អ្នកសម្រេចវឌ្ឍនភាពជាបន្តបន្ទាប់ ឆ្ពោះទៅកាន់ការលុបបំបាត់មូលហេតុជាឫសគល់នៃអយុត្តិធម៌ និងវិសមភាព?
- តើអ្នកពាក់ព័ន្ធយ៉ាងដូចម្តេចជាមួយភាគីពាក់ព័ន្ធសំខាន់ៗដែលអាចជំរុញការផ្លាស់ប្តូរនៅក្នុងច្បាប់ និងគោលនយោបាយ ក៏ដូចជា នៅក្នុងនិយាមអាកប្បកិរិយា និងឥរិយាបថវប្បធម៌សង្គម?
- តើអ្វីទៅគឺជាគោលវិធីមានជោគជ័យដើម្បីទទួលបានការគាំទ្រចំពោះកម្មវិធីរបស់អ្នកពីភាគីពាក់ព័ន្ធផ្សេងៗ?

# ជំពូកទី១

# អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី២



# ជំពូកទី១ / អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី២




### សិទ្ធិស្ត្រី និងសមភាពយេនឌ័រ

**យើងនឹងជំរុញសិទ្ធិរបស់ស្ត្រី និងកុមារី និងលើកស្ទួយសមភាពយេនឌ័រ។**

ការសម្រេចសមភាពយេនឌ័រ គឺជាសមាសភាគដ៏សំខាន់សម្រាប់ការអភិវឌ្ឍផ្នែកសង្គមសេដ្ឋកិច្ចនៃសង្គមមានសន្តិភាព។ ប៉ុន្តែ ស្ត្រីនិងកុមារីជាច្រើននៅតែរងការរើសអើង និងជួបប្រទះនូវការផាត់ចេញពីអំណាច ការអប់រំ និងកាលានុវត្តភាពសម្រាប់ឯករាជភាពផ្នែកហិរញ្ញវត្ថុ។ លទ្ធភាពទទួលបានធនធានផ្នែកនយោបាយ និងសេដ្ឋកិច្ចដ៏សំខាន់ទាំងនេះ អនុញ្ញាតឱ្យ ស្ត្រីនិងកុមារីកាន់តែច្រើនបានចូលរួមយ៉ាងពេញលេញ ក្នុងសង្គម និងសម្រេចសក្តានុពលពិតរបស់ពួកគេ។ អង្គការសង្គមស៊ីវិលត្រូវតែជំរុញឥរិយាបថ និងអាកប្បកិរិយាទាំងឡាយដែលធានាឱ្យបានប្រាកដថាកាលានុវត្តភាព សិទ្ធិ និង ករណីយកិច្ចរបស់ស្ត្រី និងបុរសត្រូវបានទទួលស្គាល់ និងត្រូវបានគោរព នៅក្នុងគ្រប់វិស័យនៃជីវិត រួមទាំងនៅក្នុងអង្គការរបស់ពួកគេផ្ទាល់។

### សកម្មភាពគន្លឹះ:

២.១
ស្តាប់ស្ត្រី បុរស កុមារី និងកុមារាដើម្បីយល់ និងដោះស្រាយមូលហេតុជាឫសគល់ និងឥទ្ធិពលនៃការរើសអើង និង វិសមភាពយេនឌ័រ។

២.២
ដឹកនាំដោយធ្វើជាគំរូ៖ ដោះស្រាយវិសមភាពយេនឌ័រ និងធានាឱ្យបានប្រាកដសិទ្ធិនារីត្រូវបានគោរពនៅក្នុងអ្វីៗទាំងអស់ដែលយើងធ្វើ។

២.៣
ផ្តល់ភាពអង់អាចដល់ស្ត្រី និងកុមារីដើម្បីមានជីវិតពេញលេញ។

២.៤
សហការយ៉ាងជិតស្និទ្ធជាមួយគ្រប់មជ្ឈដ្ឋាននៃសង្គម រួមទាំងបុរស និងកុមារា ដើម្បីជំរុញការផ្លាស់ប្តូរជាប់លាប់ផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម ឆ្ពោះទៅកាន់សិទ្ធិរបស់ស្ត្រី និងកុមារី និង សមភាពយេនឌ័រ។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

## កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជាការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល ធ្វើការវិភាគ និងពិភាក្សាយេនឌ័រដែលមានលក្ខណៈចូលរួម និងជាប្រព័ន្ធយ៉ាងទៀងទាត់ និងអនុវត្តការផ្លាស់ប្តូរចាំបាច់នានា រួមជាមួយភាគីពាក់ព័ន្ធរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល ជំរុញ និងជ្រោងភាពអង់អាចរបស់ស្ត្រី និងសមភាពយេនឌ័រ នៅក្នុងកម្មវិធីគោលនយោបាយ រចនាសម្ព័ន្ធ និងការអនុវត្តរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល និងកម្មវិធីរបស់ខ្លួន បង្កើតកាលានុវត្តភាព ដើម្បីឱ្យស្ត្រី និងកុមារីមានសិទ្ធិនិងករណីយកិច្ចដូចគ្នានៅក្នុងគ្រប់វិស័យនៃជីវិតដូចជាបុរស និងកុមារាអញ្ចឹងដែរ។
- អង្គការសង្គមស៊ីវិល ចាត់ទុកយ៉ាងជាក់លាក់ថាបុរស និងកុមារា ជាភាគីពាក់ព័ន្ធដ៏សំខាន់នៅក្នុងទំនាក់ទំនងសង្គមទូទៅ។
- អង្គការសង្គមស៊ីវិល សហការជាមួយក្រុមភាគីពាក់ព័ន្ធផ្សេងៗ ក្នុងការជំរុញនិងគោរពសិទ្ធិនារីរួមទាំងស្ត្រីដែលពិបាកឈោងដល់។
- អង្គការសង្គមស៊ីវិល ផ្តល់ការបណ្តុះបណ្តាលបុគ្គលិកប្រកបដោយប្រសិទ្ធភាព លើប្រធានបទនានា ដូចជាការវិភាគយេនឌ័រ ការរៀបចំកម្មវិធីយេនឌ័រសមភាពនិងសមធម៌យេនឌ័រអត្តសញ្ញាណយេនឌ័រ និងយេនឌ័រទាក់ទិននឹងសិទ្ធិ។
- កិច្ចដំណើរការរៀបចំផែនការរបស់អង្គការសង្គមស៊ីវិល រួមបញ្ចូលការពិគ្រោះយោបល់ជាមួយអ្នកដែលត្រូវបានគេដាក់នៅក្រៅដោយសារភេទរបស់ពួកគេ ជាពិសេស ស្ត្រីនិងកុមារី ដើម្បីឱ្យមានការវិភាគបរិបទលើឧបសគ្គចំពោះការដាក់បញ្ចូលពួកគេ និងការកំណត់កាលានុវត្តភាពសម្រាប់ការចូលរួមរបស់ពួកគេ។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

- អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែតសេចក្តីថ្លែងការណ៍ដៃគូមតិកែលម្អ និងយន្តការដោះស្រាយបណ្តឹងឬប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖
- ស្ត្រីនិងកុមារី យល់ថាកម្មវិធីរបស់អង្គការសង្គមស៊ីវិលឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់លាក់ និងកាលានុវត្តភាពរបស់ពួកគេ ទន្ទឹមគ្នានឹងការទទួលស្គាល់វប្បធម៌របស់ពួកគេផងដែរ។
- ភាគីពាក់ព័ន្ធ ជាពិសេស ស្ត្រីនិងកុមារី យល់ថាអង្គការសង្គមស៊ីវិលជំរុញ និងលើកស្ទួយប្រកបដោយជោគជ័យនូវការសម្រេចសមភាពយេនឌ័រ។
- បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត យល់ថាអង្គការសង្គមស៊ីវិល ផ្តល់កាលានុវត្តភាពស្មើគ្នាជូនស្ត្រីនៅក្នុងអង្គការ និងទទួលស្គាល់សេចក្តីត្រូវការជាក់លាក់របស់ពួកគេ។
- ស្ត្រីនិងកុមារី ពេញចិត្តនឹងព័ត៌មាន និងកាលានុវត្តភាពដែលពួកគេមានដើម្បីជំរុញសិទ្ធិរបស់ពួកគេ។
- ភាគីពាក់ព័ន្ធ ជាពិសេស ស្ត្រីនិងកុមារី យល់ថាអង្គការសង្គមស៊ីវិល ធ្វើការជាមួយភាគីពាក់ព័ន្ធសំខាន់ៗ និងអង្គការនានាដើម្បីមានផលប៉ះពាល់ប្រកបដោយអត្ថន័យលើមូលហេតុជាប្រព័ន្ធនិងផ្នែកវប្បធម៌នៃការរើសអើងទាក់ទិននឹងយេនឌ័រ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្វីទៅ គឺជាផលប៉ះពាល់នៃការងាររបស់អ្នក ដែលរួមចំណែកយ៉ាងជាក់លាក់ដល់ការសម្រេចសិទ្ធិ និងសមភាពយេនឌ័ររបស់ស្ត្រី?
- តើអ្នកវាយតម្លៃរចនាសម្ព័ន្ធ និយាម អាកប្បកិរិយា និងឥរិយាបថអង្គការរបស់អ្នក ចំពោះស្ត្រីនិងបុរសយ៉ាងដូចម្តេច និងតើអ្នកធានាឱ្យបានប្រាកដនូវកាលានុវត្តភាពស្មើគ្នាសម្រាប់ពួកគេយ៉ាងដូចម្តេច?
- តើអ្នកប្រាប់ស្ត្រី និងកុមារីយ៉ាងដូចម្តេចអំពីសិទ្ធិរបស់ពួកគេ និងតើត្រូវទាមទារសិទ្ធិទាំងនេះពីអ្នកណា រួមទាំងនៅក្នុងអង្គការរបស់អ្នកផ្ទាល់? តើអ្នកគាំទ្រពួកគេយ៉ាងដូចម្តេច នៅក្នុងការទាមទារសិទ្ធិទាំងនេះ នៅក្នុងវិស័យសាធារណៈ និងឯកជន?
- តើអ្នកធានាឱ្យបានប្រាកដយ៉ាងដូចម្តេចថាការងាររបស់អ្នកសម្រេចវឌ្ឍនភាពជាបន្តបន្ទាប់ ឆ្ពោះទៅកាន់ការផ្លាស់ប្តូរជាប់លាប់ ផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គមសម្រាប់ស្ត្រី និងកុមារី?
- តើអ្នកពាក់ព័ន្ធយ៉ាងដូចម្តេចជាមួយភាគីពាក់ព័ន្ធ និងអង្គការសំខាន់ៗ ដែលអាចជំរុញការផ្លាស់ប្តូរនៅក្នុង ច្បាប់និងគោលនយោបាយ ក៏ដូចជានៅក្នុង និយាមវប្បធម៌សង្គម អាកប្បកិរិយា និងឥរិយាបថ?
- តើអ្វីទៅ គឺជាគោលវិធីប្រកបដោយជោគជ័យ ដើម្បីទទួលបានការគាំទ្រចំពោះកម្មវិធីរបស់អ្នកពីភាគីពាក់ព័ន្ធផ្សេងៗ?

# ជំពូកទី១

# អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី៣



# ជំពូកទី១ / អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី៣




### សុខុមាលភាពភពផែនដី

**យើងនឹងការពារបរិស្ថានធម្មជាតិ និងលើកស្ទួយលទ្ធភាពរបស់វាក្នុងការទ្រទ្រង់ជីវិតសម្រាប់មនុស្សជំនាន់ក្រោយ។**

---

សុខុមាលភាពភពផែនដីមួយ គឺសំខាន់ក្រៃលែងដើម្បីទ្រទ្រង់ជីវិត បច្ចុប្បន្ន និងដើម្បីធានាឱ្យបានប្រាកដថាមនុស្សជំនាន់ក្រោយទាំងអស់នឹងបន្តលូតលាស់នៅជុំវិញផែនដី។ ប៉ុន្តែ ផលវិបាកនៃទុព្វលភាពផ្នែកបរិស្ថាន ជាពិសេសការបំពុល ការប្រែប្រួលអាកាសធាតុ និងការបាត់បង់ជីវចម្រុះ ត្រូវបានទទួលរងក្នុងលក្ខណៈវិសមភាពដោយជនក្រីក្របំផុត និងជនជួបការលំបាកបំផុតនៅក្នុងសង្គម។ នៅក្នុងការស្វែងរកគោលនយោបាយ និងការប្រតិបត្តិស្អាតបាត រឹងប៉ឹង និងប្រកបដោយចីរភាព ដែលផ្តល់អត្ថប្រយោជន៍ដល់មនុស្សជាតិ និងភពផែនដី អង្គការសង្គមស៊ីវិលត្រូវរៀបចំ និងអនុវត្តយុទ្ធសាស្ត្រដែលរួមចំណែកដល់កិច្ចការពារបរិស្ថានធម្មជាតិ។ យុទ្ធសាស្ត្រទាំងនេះ ត្រូវតែចាប់ផ្តើមដោយជំរុញការផ្លាស់ប្តូរមួយ នៅក្នុងឥរិយាបថរបស់បុគ្គល រួមទាំងនៅក្នុងអង្គការរបស់យើងផ្ទាល់ ប៉ុន្តែក៏គប្បីត្រូវពិចារណាផងដែរអំពីវិធីនានាដើម្បីកែប្រែប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច។

### សកម្មភាពគន្លឹះ

៣.១
ស្តាប់ប្រជាជន និងពិគ្រោះយោបល់ជាមួយអ្នកជំនាញដើម្បីស្វែងយល់អំពីបញ្ហាបរិស្ថានដែលប្រជាជនជួបប្រទះ និងរបៀបដោះស្រាយបញ្ហាទាំងនោះឱ្យបានប្រសើរបំផុត។

៣.២
ដឹកនាំដោយធ្វើជាគំរូ៖
កំណត់ផែនទីនៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់អង្គការយើង កាត់បន្ថយឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន និងមិនលាក់បាំងជោគជ័យនិងបរាជ័យរបស់យើង។

៣.៣
លើកទឹកចិត្ត និងគាំទ្រប្រជាជនឱ្យការពារបរិស្ថាន និងជំរុញការផ្លាស់ប្តូរជាប្រព័ន្ធដើម្បីសុខុមាលភាពភពផែនដីមួយ។

៣.៤
សហការជាមួយតួអង្គមកពីវិស័យផ្សេងៗដើម្បីអភិវឌ្ឍដំណោះស្រាយបែបនវានុវត្តន៍និងជាប្រព័ន្ធចំពោះបញ្ហាបរិស្ថាន។

# សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

## កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល ធ្វើការសិក្សាវាយតម្លៃ និងការវិភាគបរិស្ថានបែបចូលរួមនិងជាប្រព័ន្ធ និងពិភាក្សាអំពីផលប៉ះពាល់ និងអនុវត្តការផ្លាស់ប្តូរចាំបាច់នានា រួមជាមួយភាគីពាក់ព័ន្ធរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល ជំរុញ និងលើកស្ទួយកិច្ចការពារបរិស្ថាននៅក្នុងកម្មវិធី កិច្ចប្រតិបត្តិការ និងគោលនយោបាយរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល មានគោលនយោបាយ និងនីតិវិធី សម្រាប់តាមដាន ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ផ្នែកបរិស្ថានរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល ផ្សព្វផ្សាយព័ត៌មានអំពីកិច្ចប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅកាន់កិច្ចការពារបរិស្ថាន និងឥទ្ធិពលផ្នែកបរិស្ថានរបស់ពួកគេ។
- អង្គការសង្គមស៊ីវិល បង្កើតកាលានុវត្តភាពសម្រាប់ឱ្យប្រជាជនការពារបរិស្ថាន និងធ្វើការលើការផ្លាស់ប្តូរជាប្រព័ន្ធ។
- អង្គការសង្គមស៊ីវិល ពាក់ព័ន្ធជាមួយតួអង្គពាក់ព័ន្ធទាំងអស់ និងប្រើគោលវិធី និងបច្ចេកទេសថ្មីៗ នៅក្នុងកិច្ចការពារបរិស្ថាន។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធយល់ថាអង្គការសង្គមស៊ីវិលឆ្លើយតបទៅនឹងបញ្ហាប្រឈម សេចក្តីត្រូវការ និងកាលានុវត្តភាពជាក់លាក់របស់ពួកគេ ទន្ទឹមគ្នានឹងទទួលស្គាល់ធនធាន និងការប្រតិបត្តិវប្បធម៌របស់ពួកគេផ្ទាល់។
- ភាគីពាក់ព័ន្ធ ទទួលស្គាល់ការខិតខំរបស់អង្គការសង្គមស៊ីវិល ដើម្បីការពារបរិស្ថាន ដឹងអំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានរបស់អង្គការ និងឯកភាពលើការខិតខំរបស់អង្គការ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។
- ភាគីពាក់ព័ន្ធ យល់ថាការងាររបស់អង្គការសង្គមស៊ីវិលបានរួមចំណែកដល់ការកើនឡើងនៃមនសិការនិង ចំណេះដឹងរបស់ពួកគេ អំពីភាពចាំបាច់ត្រូវការពារបរិស្ថាន និងអំពីមធ្យោបាយផ្សេងៗ ដើម្បីធ្វើដូច្នេះ។
- ភាគីពាក់ព័ន្ធ រាយការណ៍ថាអង្គការសង្គមស៊ីវិលបានលើកទឹកចិត្តឱ្យពួកគេចូលរួមក្នុងសកម្មភាពនានាដើម្បីការពារបរិស្ថាន ទាំងជាបុគ្គលទាំងជាសមូហភាព។
- ភាគីពាក់ព័ន្ធ យល់ថាអង្គការសង្គមស៊ីវិលរួមចំណែកប្រកបដោយអត្ថន័យដល់ការផ្លាស់ប្តូរជាប្រព័ន្ធ ដើម្បីការពារបរិស្ថាន។
- ភាគីពាក់ព័ន្ធ យល់ថាអង្គការសង្គមស៊ីវិលធ្វើការជាមួយប្រជាជន និងអង្គការចាំបាច់នានា ដើម្បីអភិវឌ្ឍដំណោះស្រាយបែបនវានុវត្តន៍។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកធ្វើដូចម្ដេចទើបដឹងថា ជំហានទាំងឡាយដែលអ្នកបានអនុវត្តដើម្បីកាត់បន្ថយ ផលប៉ះពាល់អវិជ្ជមានផ្នែក បរិស្ថានរបស់អ្នកមានប្រសិទ្ធភាព ?
- តើអ្នកចែករំលែកអ្វីដែលអ្នកបានរៀនសូត្រពីការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់អ្នកជាមួយអ្នកដទៃយ៉ាងដូចម្ដេច ?
- តើអ្នកអប់រំប្រជាជនអំពីផលប៉ះពាល់របស់ពួកគេលើបរិស្ថាន រួមទាំងបុគ្គលិក និងអ្នកធ្វើការដោយស្ម័គ្រចិត្តរបស់អង្គការរបស់អ្នកផ្ទាល់យ៉ាងដូចម្ដេច ?
- តើអ្នកធ្វើដូចម្ដេចទើបដឹងថាការគាំទ្ររបស់អ្នកមានប្រយោជន៍ ក្នុងការជួយឱ្យប្រជាជនអាចការពារបរិស្ថានដោយខ្លួនឯង ?
- តើអ្នកពាក់ព័ន្ធយ៉ាងដូចម្ដេចជាមួយតួអង្គផ្សេងៗទៀតដែលអាចជំរុញការផ្លាស់ប្ដូរនៅក្នុងច្បាប់និងគោលនយោបាយ បច្ចេកវិទ្យាថ្មី ក៏ដូចជានៅក្នុងអាកប្បកិរិយា និងឥរិយាបថវប្បធម៌សង្គម ?
- តើអ្នកធានាឱ្យបានប្រាកដយ៉ាងដូចម្ដេចថាការងាររបស់អ្នកសម្រេចវឌ្ឍនភាពជាបន្តបន្ទាប់ឆ្ពោះទៅកាន់ចីរភាពវិជ្ជមានជាប់លាប់ផ្នែកបរិស្ថាន ?

# ជំពូកទី១

# អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី៤



# ជំពូកទី១ / អ្វីដែលយើងចង់សម្រេចបាន

## គោលការណ៍អនុវត្តទី៤




### ការផ្លាស់ប្តូរវិជ្ជមានជាប់លាប់

**យើងនឹងសម្រេចលទ្ធផលវិជ្ជមាន រយៈពេលវែង**

---

ការសម្រេចគោលបំណងរួមនៃបរិយាប័ន្នសង្គមកិច្ចការពារបរិស្ថាន និងកំណើនសេដ្ឋកិច្ច នាពេលបច្ចុប្បន្ន មិនត្រូវប៉ះពាល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយក្នុងការបំពេញសេចក្តីត្រូវការ របស់ពួកគេឡើយ។ ការផ្លាស់ប្តូរវិជ្ជមានជាប់លាប់ តម្រូវឱ្យអង្គការសង្គមស៊ីវិលប្រកាន់យកយុទ្ធសាស្ត្ររយៈពេលវែង ក្នុងភាពជាដៃគូជាមួយតួអង្គ និងអង្គការដទៃទៀត។ គោលវិធីរយៈពេលវែង និងបែបបរិយាប័ន្នមួយដែលដោះស្រាយមូលហេតុជាឫសគល់នៃបញ្ហាបច្ចុប្បន្ន និងដែលផ្តោតលើការសម្រេចផលប៉ះពាល់ប្រកបដោយចីរភាពនឹងរួមចំណែកដល់ការបង្កើនទំនុកចិត្ត និងនីត្យានុកូលភាពរបស់អង្គការសង្គមស៊ីវិល។

### សកម្មភាពគន្លឹះ

៤.១
រៀនសូត្រពីប្រជាជននិងដៃគូ ដែលនៅក្នុងនោះ យើងអាចបន្ថែមគុណតម្លៃច្រើនបំផុតទៅលើអ្វីដែលមានរួចស្រេចហើយ។

៤.២
គាំទ្រប្រជាជនដើម្បីឱ្យមានព័ត៌មាន ធនធាន និងសមត្ថភាព ដើម្បីជំរុញយ៉ាងសកម្មនូវការផ្លាស់ប្តូរដែលយើងចង់ឃើញជាសមូហភាព។

៤.៣
វាយតម្លៃលទ្ធផលរយៈពេលវែងរបស់យើង ដោយពិគ្រោះយោបល់ជាមួយប្រជាជនដែលយើងធ្វើការជាមួយ រួមទាំងឥទ្ធិពលអវិជ្ជមានដែលមិនចង់បាន។

៤.៤
សហការជាមួយតួអង្គដទៃទៀត តាមវិធីនានា ដែលកសាងលើចំណុចខ្លាំងទៅវិញទៅមក និងធានាឱ្យបានប្រាកដនូវគណនេយ្យភាពសម្រាប់ផលប៉ះពាល់រួមរបស់យើង។

៤.៥
តាមដាន វាយតម្លៃ រៀនសូត្រ សម្រប និងផ្តួចផ្តើម ដោយផ្តោតលើលទ្ធផលជាប់លាប់។

# សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

## កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល ផ្តោតការយកចិត្តទុកដាក់លើការស្តាប់ ការចែករំលែក និងការបង្កើតរួមគ្នានូវដំណោះស្រាយនានា ជាមួយគំនិតផ្តួចផ្តើមមានស្រាប់ និងភាគីពាក់ព័ន្ធដែលអាចមាន។
- អង្គការសង្គមស៊ីវិល ធ្វើការវិភាគបែបចូលរួមលើសេចក្តីត្រូវការ បរិបទ និងភាគីពាក់ព័ន្ធ ដើម្បីកំណត់អ្វីដែលកំពុងដំណើរការបានល្អរួចហើយ និងនៅកន្លែងណា និងជាមួយអ្នកណាដែលអង្គការអាចសម្រេចផលប៉ះពាល់ច្រើនបំផុតជាមួយអ្នកដែលខ្លួនមានបំណងគាំទ្រ ឬ ជួយការពារ។
- អង្គការសង្គមស៊ីវិល តាមដានកិច្ចដំណើរការវាយតម្លៃរៀនសូត្រ និងនវានុវត្តន៍ ជាមួយអ្នកដែលខ្លួនតំណាងឱ្យធ្វើការជាមួយ និងជួយការពារ។
- អង្គការសង្គមស៊ីវិល តាមដាន និងវាយតម្លៃផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាននៃការងាររបស់ខ្លួន និងរៀបចំយុទ្ធសាស្ត្រដើម្បីពង្រឹងបន្ថែម ឬ កាត់បន្ថយផលប៉ះពាល់ទាំងនោះ។
- អង្គការសង្គមស៊ីវិល វាយតម្លៃកម្រិតដែលគំនិតផ្តួចផ្តើមរបស់ខ្លួននាំទៅ ដល់ការផ្លាស់ប្តូររឹងមាំ និងជាប់លាប់ និងកែសម្រួលយុទ្ធសាស្ត្ររបស់ខ្លួន ប្រសិនបើចាំបាច់។
- ទិន្នន័យនៃការតាមដាន និងការវាយតម្លៃ ផ្តល់ព័ត៌មានដល់ការសម្របតាមបែបនវានុវត្តនៅក្នុងការរៀបចំកម្មវិធី និងការអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រនានា ហើយទិន្នន័យនេះក៏ត្រូវបានចែករំលែកជាមួយដៃគូផងដែរ។
- អង្គការសង្គមស៊ីវិល រក្សាភាពទន់ភ្លន់ក្នុងកម្រិតមួយ ដើម្បីធ្វើការឆ្ពោះទៅកាន់លទ្ធផលប្រកបដោយចីរភាព ជាមួយដៃគូ និងអ្នកដែលតំណាងឱ្យ ធ្វើការជាមួយ និងជួយការពារ។
- អង្គការសង្គមស៊ីវិល សហការជាមួយភាគីពាក់ព័ន្ធសំខាន់ៗផ្សេងៗគ្នា ដែលចាំបាច់ត្រូវចូលរួមដើម្បីជំរុញការផ្លាស់ប្តូរវិជ្ជមានជាប់លាប់។
- អង្គការសង្គមស៊ីវិល មានយុទ្ធសាស្ត្រច្បាស់លាស់មួយដើម្បីបញ្ឈប់បន្តិចម្តងៗនូវការងាររបស់ខ្លួន និងដើម្បីប្រគល់ការទទួលខុសត្រូវ និងការរៀបចំឯកសារជូនភាគីពាក់ព័ន្ធ។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធ យល់ថាអង្គការសង្គមស៊ីវិល រួមចំណែកដល់ និងកសាងលើគំនិតផ្តួចផ្តើមមានស្រាប់ ឬ គំនិតផ្តួចផ្តើមមុនៗ ជាជាងធ្វើការត្រួតគ្នា ឬ ជំនួសគំនិតផ្តួចផ្តើមទាំងនោះ។
- ភាគីពាក់ព័ន្ធ យល់ថាការងាររបស់អង្គការសង្គមស៊ីវិល ដោះស្រាយមូលហេតុជាឫសគល់ និងរួមចំណែកដល់ ការផ្លាស់ប្តូរជាប្រព័ន្ធ។
- ភាគីពាក់ព័ន្ធទទួលស្គាល់លទ្ធផលរយៈពេលវែងនៃកម្មវិធីរបស់អង្គការសង្គមស៊ីវិល។

- ភាគីពាក់ព័ន្ធ យល់ថាពួកគេអាចមានឥទ្ធិពលលើការផ្លាស់ប្ដូរ តាមរយៈធាតុចូលរបស់ពួកគេ។
- ភាគីពាក់ព័ន្ធ ជឿថាចំណុចខ្លាំង កាលានុវត្តភាព និងផលប៉ះពាល់របស់ពួកគេត្រូវបានលើកស្ទួយ តាមរយៈ កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល។
- ភាគីពាក់ព័ន្ធ បន្តធ្វើការឆ្ពោះទៅកាន់គោលបំណងរួម ក្រោយពេលអង្គការសង្គមស៊ីវិលបានបញ្ចប់ការពាក់ព័ន្ធរបស់ខ្លួន។
- គណៈគ្រប់គ្រង បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត យល់ថាកម្មវិធីរបស់អង្គការសង្គមស៊ីវិល ឆ្លើយតបទៅនឹងបរិបទប្រតិបត្តិការ រួមមានការផ្លាស់ប្ដូរទិសដៅនៅក្នុង បរិស្ថាននយោបាយ និងប្រភពផ្ដល់មូលនិធិ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកកំណត់អត្តសញ្ញាណ និងពាក់ព័ន្ធយ៉ាងដូចម្ដេចជាមួយកម្មវិធីរបស់អាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន ក៏ដូចជាអង្គការដទៃទៀតនៅពេលរៀបចំ ធ្វើផែនការ និងអនុវត្តកម្មវិធីរបស់អ្នក?
- តើអ្នករួមចំណែកដល់លទ្ធភាពរបស់ប្រជាជនក្នុងការដឹកនាំការផ្លាស់ប្ដូរ យ៉ាងដូចម្ដេច?
- តើអ្នកណាខ្លះចូលរួមក្នុងការតាមដាន និងការវាយតម្លៃលទ្ធផលកម្មវិធី និងលទ្ធផលរយៈពេលវែងនៃអង្គការរបស់អ្នក?
- តើអ្នកធានាយ៉ាងដូចម្ដេចឱ្យបានប្រាកដថា ការប្រតិបត្តិប្រសើរបំផុតនិងមេរៀនដែលបានទទួលត្រូវបានកំណត់ ចងក្រង និងចែករំលែកជាមួយភាគីពាក់ព័ន្ធ?
- តើអ្នករួមចំណែក ដល់ការពង្រឹងការផ្សារភ្ជាប់បណ្ដាញមូលដ្ឋាន និងកាលានុវត្តភាពរៀនសូត្រយ៉ាងដូចម្ដេច?
- តើអ្វីទៅគឺជាទ្រឹស្ដីរបស់អ្នកអំពីការផ្លាស់ប្ដូរ និងតើអ្នកធានាយ៉ាងដូចម្ដេចឱ្យបានប្រាកដថាទ្រឹស្ដីនោះនៅតែមានសុពលភាព និងត្រូវបានបង្កប់នៅក្នុងការងាររបស់អ្នក?
- តើអ្នកធានាឱ្យបានយ៉ាងដូចម្ដេចនូវភាពជាម្ចាស់សមត្ថភាព និងគោលវិធីជាប្រព័ន្ធ ដើម្បីរក្សាផលប៉ះពាល់នៃការងាររបស់អ្នក?

# ជំពូកទី២

# គោលវិធីរបស់យើងចំពោះ ការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៥



# ជំពូកទី២ / គោលវិធីរបស់យើងចំពោះការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៥




ការងារដែលនាំមុខដោយប្រជាជនយ៉ាងពិតប្រាកដ តម្រូវឱ្យធនធាននិងអំណាចដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់អង្គការសង្គមស៊ីវិល ត្រូវចែករំលែកឱ្យបានគ្រប់គ្រាន់រវាងអង្គការ និងប្រជាជន។ លុះត្រាណាតែប្រជាជន និងអង្គការសង្គមស៊ីវិលចែករំលែកភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់លើកិច្ចដំណើរការសំដៅសម្រេចគោលបំណងរួមតែប៉ុណ្ណោះ ទើបលទ្ធផលជាប់លាប់វិជ្ជមាន អាចសម្រេចបាន ហើយគំនិតផ្តួចផ្តើមក្នុងមូលដ្ឋានត្រូវបានពង្រឹង។ ការធានាឱ្យបានប្រាកដថា ពួកគេស្តាប់ និងពាក់ព័ន្ធប្រជាជនយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត នឹងធ្វើឱ្យការងាររបស់អង្គការសង្គមស៊ីវិលមានលក្ខណៈកាន់តែសមស្របចំពោះប្រជាជន និងកាន់តែមានប្រសិទ្ធភាព។

### ការងារនាំមុខដោយប្រជាជន

**យើងនឹងធានាឱ្យបានប្រាកដថាប្រជាជនដែលយើងធ្វើការជាមួយមានតួនាទីគន្លឹះមួយក្នុងការជំរុញការងាររបស់យើង។**

### សកម្មភាពគន្លឹះ

៥.១
រៀនសូត្រពីប្រជាជនដែលយើងធ្វើការជាមួយ និងតំណាងឱ្យ ដើម្បីប្រែក្លាយបញ្ហារបស់ពួកគេទៅជាគោលដៅរបស់យើង។

៥.២
គាំទ្រប្រជាជនក្នុងការប្រកាន់យកតួនាទីដ៏សកម្មដើម្បីជំរុញការផ្លាស់ប្តូរ ដែលយើងចង់ឃើញជាសមូហភាព។

៥.៣
ធានាឱ្យបានប្រាកដថាទស្សនៈរបស់ប្រជាជនត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ នៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត នៅគ្រប់កម្រិតនៃអង្គការរបស់យើង។

៥.៤
ស្នើសុំ និងធ្វើសកម្មភាពតាមមតិកែលម្អរបស់ប្រជាជន ដើម្បីកែលម្អការអនុវត្តការងារ និងផលប៉ះពាល់រួមរបស់យើង។

## កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិលប្រើវិធីសាស្រ្តមានប្រសិទ្ធភាពសម្រាប់ការវិភាគភាគីពាក់ព័ន្ធនៅក្នុងសកម្មភាពរបស់អង្គការ។
- ម្ចាស់សិទ្ធិ និងភាគីពាក់ព័ន្ធសំខាន់ៗ ចូលរួមយ៉ាងសកម្មនៅក្នុងការវិភាគបរិបទ ការរៀបចំផែនការយុទ្ធសាស្រ្ត ការអនុវត្ត ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីរបស់អង្គការសង្គមស៊ីវិល។
- អង្គការសង្គមស៊ីវិល បកប្រែកម្មវិធីនិងព័ត៌មានអង្គការទៅជាភាសាក្នុងស្រុក និងក្នុងទម្រង់សមស្រប។
- ការសម្រេចចិត្តរបស់អង្គការសង្គមស៊ីវិលនៅគ្រប់កម្រិត ឆ្លុះបញ្ចាំងសេចក្តីត្រូវការ អាទិភាព និងគោលបំណងរួម ដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធរបស់អង្គការសង្គមស៊ីវិល។
- មតិកែលម្អ ត្រូវបានប្រើដើម្បីជះឥទ្ធិពលលើការសម្រេចចិត្តរបស់អង្គការសង្គមស៊ីវិល និងដើម្បីធ្វើការផ្លាស់ប្តូរ ដើម្បីកែលម្អស្នាដៃការងារ និងផលប៉ះពាល់។
- អង្គការសង្គមស៊ីវិល ជំរុញសម្លេងរបស់ប្រជាជនដែលពួកគេធ្វើការជាមួយ នៅក្នុងការប្រាស្រ័យទាក់ទង ជាមួយសាធារណជន និងភាគីពាក់ព័ន្ធខាងក្រៅ។
- មានយន្តការផ្លូវការសម្រាប់ឱ្យភាគីពាក់ព័ន្ធផ្តល់គំនិតនិងមតិកែលម្អរបស់ពួកគេ។
- អង្គការសង្គមស៊ីវិលវិភាជធនធានដើម្បីការអភិវឌ្ឍសមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីពង្រឹងការដឹកនាំរបស់ពួកគេក្នុងការអនុវត្តគំនិតផ្តួចផ្តើមរបស់ពួកគេផ្ទាល់។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានព័ត៌មានអង្គការ និងកម្មវិធីពីអង្គការសង្គមស៊ីវិល។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងកម្រិតចូលរួមរបស់ពួកគេនៅក្នុងការងាររបស់អង្គការសង្គមស៊ីវិល។
- ភាគីពាក់ព័ន្ធរាយការណ៍ថាកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលបានបង្កើនជំនឿជាក់របស់ពួកគេក្នុងការដឹកនាំគំនិតផ្តួចផ្តើមរបស់ពួកគេ។
- ភាគីពាក់ព័ន្ធ ជឿថាអង្គការសង្គមស៊ីវិលស្តាប់ពួកគេ និងថាការងាររបស់អង្គការកំពុងជួយពួកគេឱ្យសម្រេច គោលបំណងរបស់ពួកគេ។
- ភាគីពាក់ព័ន្ធ ដឹងអំពីយន្តការផ្តល់មតិកែលម្អដែលអង្គការសង្គមស៊ីវិលមាន និងប្រើយន្តការទាំងនោះយ៉ាងសកម្ម។

- ភាគីពាក់ព័ន្ធ ជឿថាអង្គការសង្គមស៊ីវិលប្រមូល វិភាគ ប្រើ និងឆ្លើយតបទៅនឹងមតិកែលម្អបាន គ្រប់គ្រាន់។
- ភាគីពាក់ព័ន្ធ មើលឃើញការផ្លាស់ប្តូរវិជ្ជមាន ជាការឆ្លើយតបទៅនឹងមតិកែលម្អទាំងឡាយដែល ពួកគេផ្តល់។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើប្រជាជនណាខ្លះដែលអ្នកបានរៀនសូត្រពីពួក គាត់? តើអ្នក រៀនសូត្រពីពួកគាត់យ៉ាងដូច ម្តេច?
- តើអ្នកធានាយ៉ាងដូចម្តេច ឱ្យបានប្រាកដថា ទស្សនៈ និងគំនិតរបស់ប្រជាជន ត្រូវបានឆ្លុះ បញ្ចាំងនៅក្នុង ការងាររបស់អង្គការអ្នក។
- តើអ្នកណាកំពុងបំពេញតួនាទីដ៏សកម្មមួយនៅ ក្នុងការជំរុញការងាររបស់អង្គការរបស់អ្នក។
- តើអ្នកធានាយ៉ាងដូចម្តេចឱ្យបានប្រាកដថាប្រជា ជន និងដៃគូមានមធ្យោបាយនិងទឹកចិត្ត ក្នុងការ រក្សានិងជំរុញការផ្លាស់ប្តូរដែលអ្នកបានសម្រេច ជាសមូហភាព?
- តើអ្នកជួយនិងគាំទ្រភាគីពាក់ព័ន្ធសំខាន់ៗយ៉ាង ដូចម្តេច នៅក្នុងការបំពេញតួនាទីដ៏សកម្ម និង ភាពជាអ្នកដឹកនាំក្នុងការដោះស្រាយបញ្ហាទាំង ឡាយដែលពួកគេជួបប្រទះ? តើអ្នកផ្តល់វិធី សាស្រ្ត និងធនធានអ្វីខ្លះ?
- តើអ្នកស្នើសុំ ប្រមូល វិភាគ ពិភាក្សា ឆ្លើយតប និង ធ្វើសកម្មភាពយ៉ាងដូចម្តេចទៅនឹងមតិកែលម្អ និង បណ្តឹងនានា?

# ជំពូកទី២

# គោលវិធីរបស់យើងចំពោះ ការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៦



# ជំពូកទី២ / គោលវិធីរបស់យើងចំពោះការផ្លាស់ប្ដូរ

## គោលការណ៍អនុវត្តទី៦




### ភាពជាដៃគូរឹងមាំ

យើងនឹងធ្វើការក្នុងភាពជាដៃគូប្រកបដោយយុត្តិធម៌ និងក្ដីគោរព ដើម្បីសម្រេចគោលបំណងរួម។

ភាពជាដៃគូរឹងមាំ ត្រូវបានកសាងលើទំនាក់ទំនងប្រកបដោយតម្លាភាព និងមានលក្ខណៈគាំទ្រគ្នា និងមានសារៈសំខាន់សម្រាប់ឱ្យអង្គការសង្គមស៊ីវិលបំពេញគោលបំណងនិងគោលដៅរួម។ កិច្ចសហការ និងការសម្របសម្រួលជាមួយតួអង្គដទៃទៀត ជួយអង្គការសង្គមស៊ីវិលក្នុងការប្រកាន់យកគោលវិធីទាំងមូល កំណត់គម្លាត និងក្នុងការទប់ស្កាត់កិច្ចប្រឹងប្រែងត្រួតគ្នា នៅក្នុងការសម្រេចលទ្ធផលរួម។ ចំណុចខ្លាំងនិងទស្សនៈផ្សំគ្នារបស់តួអង្គផ្សេងៗ អាចជួយក្នុងការសម្រេចគោលបំណង ក្នុងលក្ខណៈកាន់តែមានប្រសិទ្ធផល និងជាមួយផលប៉ះពាល់កាន់តែច្រើន។ អង្គការសង្គមស៊ីវិល ត្រូវខិតខំពង្រឹងការផ្សារភ្ជាប់រវាងតួអង្គផ្សេងៗ និងព្យាយាមលើកកម្ពស់លទ្ធភាពរបស់ពួកគេ ក្នុងការធ្វើការរួមគ្នាដើម្បីដោះស្រាយនៅក្នុងបញ្ហាស្មុគ្រស្មាញនានាក្នុងរយៈពេលវែង។

### សកម្មភាពគន្លឹះ

៦.១
កំណត់អត្តសញ្ញាណអង្គការដែលធ្វើការ ឆ្ពោះទៅកាន់គោលបំណងដូចគ្នា និងកសាងភាពជាដៃគូប្រកបដោយក្ដីគោរព ដែលផ្ដោតលើចំណុចខ្លាំងរបស់គ្នាទៅវិញទៅមក។

៦.២
ធានាឱ្យបានប្រាកដថាតួនាទី និងការទទួលខុសត្រូវរបស់អង្គការ និងដៃគូយើង មានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវ។

៦.៣
សហការជាមួយអង្គការប្រភេទផ្សេងៗដើម្បីសម្រេចគោលបំណងរួម។

៦.៤
ចែករំលែកព័ត៌មាន ធនធាន និងចំណេះដឹង និងធ្វើការសម្រេចចិត្តសំខាន់ៗជាសមូហភាព។

# សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

## កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល ធ្វើការវិភាគបរិបទនិងភាគីពាក់ព័ន្ធ ទៀងទាត់ ដើម្បីកំណត់អត្តសញ្ញាណ និងលំដាប់អាទិភាពនៃដៃគូ ដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់។
- អង្គការសង្គមស៊ីវិល មានគោលការណ៍ណែនាំ និងគោលនយោបាយស្តីពីគោលការណ៍ភាពជាដៃគូ គុណតម្លៃ និងគោលវិធីរបស់ខ្លួន និងចែករំលែកឯកសារទាំងនេះជាមួយដៃគូរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល ធ្វើការជាមួយដៃគូរបស់ខ្លួន ដើម្បីរៀបចំផែនការ និងចងក្រងជាឯកសារនូវផលប៉ះពាល់រួម។
- អង្គការសង្គមស៊ីវិលនិងដៃគូរបស់ខ្លួន ចែករំលែកយន្តការ និងឧបករណ៍រួមដែលមានលក្ខណៈទាំងផ្លូវការ និងក្រៅផ្លូវការ សម្រាប់ការរៀបចំផែនការ ការតាមដាន ការប្រាស្រ័យទាក់ទង ការសម្របសម្រួល ការធ្វើសេចក្តីសម្រេចចិត្ត ការវាយតម្លៃ និងការដោះស្រាយវិវាទ។
- កិច្ចព្រមព្រៀងភាព ជាដៃគូរបស់អង្គការសង្គមស៊ីវិល បានកំណត់យ៉ាងច្បាស់នូវតួនាទី ការទទួលខុសត្រូវ និងគោលការណ៍អនុវត្តសម្រាប់ដៃគូនីមួយៗ និងចែងលម្អិតនូវរបៀបដែលដៃគូនីមួយៗនឹងរួមចំណែក ដល់ការសម្រេចគោលបំណងរួម។
- អង្គការសង្គមស៊ីវិល និងដៃគូរបស់ខ្លួន យកចិត្តទុកដាក់លើការកសាងបណ្តាញ ការផ្លាស់ប្តូរគំនិតគ្នា និងការរៀនសូត្រពីគ្នាទៅវិញទៅមក។
- អង្គការសង្គមស៊ីវិល ពិនិត្យមើលឡើងវិញនូវកិច្ចព្រមព្រៀងផ្លូវការជាមួយដៃគូ តាមរយៈកិច្ចដំណើរការមួយដែលលើកទឹកចិត្តដល់ការពិភាក្សា និងមតិកែលម្អទៅវិញទៅមក។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ដៃគូ និងភាគីពាក់ព័ន្ធទាំងអស់ ពេញចិត្តនឹងគោលការណ៍ គុណតម្លៃ និងគោលវិធីនៃភាពជាដៃគូ និងយល់ថាភាពជាដៃគូគឺត្រឹមត្រូវ និងមានប្រសិទ្ធភាព។
- ដៃគូទាំងអស់ ចាត់ទុកថាភាពជាដៃគូគឺផ្អែកលើការគោរពគ្នា គោលបំណងរួម និងគណនេយ្យភាពរួម។
- ដៃគូទាំងអស់ ដឹងអំពីកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងគិតថាជំហររបស់ពួកគេត្រូវបានគេគោរពយ៉ាងគ្រប់គ្រាន់។
- ដៃគូនិងភាគីពាក់ព័ន្ធ គិតថាកិច្ចសហការពង្រឹងទាំងកិច្ចប្រឹងប្រែង ទាំងផលប៉ះពាល់របស់អង្គការ។
- ដៃគូទាំងអស់ យល់ថាបានទទួលព័ត៌មានពេញលេញ តាមរយៈឯកសារនិងជនបង្គោល និងអាចដើរតាមគោលបំណងរួមរបស់ពួកគេ។

# សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកបន្ថែមគុណតម្លៃដល់ការងាររបស់ដៃគូមានស្រាប់ និងដៃគូដែលអាចមាន យ៉ាងដូចម្តេច?
- តើអ្វីទៅ គឺជាតួនាទីនិងការទទួលខុសត្រូវគន្លឹះសម្រាប់ ដៃគូនីមួយៗ អាស្រ័យលើចំណុចខ្លាំង សមត្ថភាព និងអាទិភាពរបស់អ្នក?
- តើកិច្ចសហការរបស់អ្នករួមចំណែកយ៉ាងដូចម្តេចដល់ ការពង្រឹងសមត្ថភាព មធ្យោបាយ ជំនឿលើខ្លួនឯង និងចំណុចខ្លាំងផ្នែកស្ថាប័នរបស់ដៃគូនីមួយៗ ហួសពីអន្តរាគមន៍ភ្លាមៗរបស់អ្នក?
- តើអ្នកធានាឱ្យបានប្រាកដនូវផលប៉ះពាល់ និងការផ្លាស់ប្តូរតាមរយៈកិច្ចសហការ និងនវានុវត្តន៍ យ៉ាងដូចម្តេច?
- តើអ្នកធានាយ៉ាងដូចម្តេចឱ្យបានប្រាកដថាការសម្រេចចិត្តសំខាន់ៗត្រូវបានធ្វើដោយសហការគ្នា?
- តើអ្នកដោះស្រាយវិវាទ ឬបញ្ហាប្រឈមនៅក្នុងភាពជាដៃគូរបស់អ្នកយ៉ាងដូចម្តេច?

# ជំពូកទី២

# គោលវិធីរបស់យើងចំពោះ ការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៧



# ជំពូកទី២ / គោលវិធីរបស់យើងចំពោះការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៧




### តស៊ូមតិដើម្បីការផ្លាស់ប្តូរជាមូលដ្ឋាន

**យើងនឹងដោះស្រាយមូលហេតុជាឫសគល់ ដោយតស៊ូមតិដើម្បីការផ្លាស់ប្តូរជាមូលដ្ឋាន។**

---

តស៊ូមតិដើម្បីការផ្លាស់ប្តូរជាមូលដ្ឋាន នៅក្នុងប្រព័ន្ធនានានៃអំណាច គឺមានសារៈសំខាន់ ដើម្បីដោះស្រាយមូលហេតុជាឫសគល់នៃអយុត្តិធម៌ ភាពក្រីក្រ ហិង្សា វិសមភាព ភាពលម្អៀងផ្នែកយេនឌ័រ និងការបំផ្លិចបំផ្លាញបរិស្ថាន។ អង្គការសង្គមស៊ីវិលត្រូវតែចូលរួមជាមួយ និងហ៊ានប្រឈមទៅនឹងគុណតម្លៃ និងអត្តសញ្ញាណដ៏ពិតប្រាកដមួយដែលរារាំងការប៉ុនប៉ង ជាសាធារណៈ និងនយោបាយដើម្បីជំនះលើឧបសគ្គ ដែលមនុស្សប្រឈមមុខ។ ដោយធ្វើឱ្យមានការទទួលស្គាល់ និងផ្តល់នូវភាពស្របច្បាប់នូវសម្លេងរបស់ប្រជាជនពាក់ព័ន្ធ។ អង្គការសង្គមស៊ីវិលបំពេញតួនាទីដ៏សំខាន់មួយក្នុងការគាំទ្រ និងធ្វើការជាមួយប្រជាជន ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យ នៅក្នុងគោលនយោបាយនៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងសកលលោក។

### សកម្មភាពគន្លឹះ៖

៧.១
ធានាឱ្យបានប្រាកដថាការងារតស៊ូមតិរបស់យើងត្រូវផ្អែកលើភស្តុតាង និងត្រូវទទួលព័ត៌មានពីប្រជាពលរដ្ឋរងផលប៉ះពាល់។

៧.២
តស៊ូមតិដើម្បីការផ្លាស់ប្តូរជាវិជ្ជមាន ដែលដោះស្រាយទាំងមូលហេតុជាឫសគល់ និងផលប៉ះពាល់របស់វា។

៧.៣
គាំទ្រប្រជាជន រួមទាំងប្រជាពលរដ្ឋរងផលប៉ះពាល់ ដើម្បីរៀនសូត្រ ផ្សារភ្ជាប់ កៀរគរ និងធ្វើឱ្យសម្លេងរបស់ពួកគេត្រូវបានគេស្តាប់ឮ។

៧.៤
កាត់បន្ថយហានិភ័យសម្រាប់ប្រជាជនដែលចូលរួមនៅក្នុង ឬ រងផលប៉ះពាល់ពីការងារតស៊ូមតិរបស់យើង។

៧.៥
វាយតម្លៃឥទ្ធិពលនៃការងារតស៊ូមតិរបស់យើងក្នុងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានាដូចជាការសិក្សាវាយតម្លៃការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អាទិភាព និងគោលវិធីនៃការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល ត្រូវបានកំណត់ដោយធាតុចូលពីភាគីពាក់ព័ន្ធសំខាន់ៗ នៅក្នុងកិច្ចដំណើរការនេះ។
- ធាតុចូលសម្រាប់ការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល គឺផ្អែកលើភស្តុតាងពីប្រភពក្នុងស្រុក និងអន្តរជាតិ។
- គោលដៅការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល គឺផ្តោតលើការផ្លាស់ប្តូរជាវិជ្ជមានរយៈពេលវែងពោល គឺមិនមែនជាសមិទ្ធផលយុទ្ធវិធីរយៈពេលខ្លីទេ។
- អង្គការសង្គមស៊ីវិល ប្រកាន់យកយុទ្ធសាស្ត្រច្បាស់លាស់មួយនៃការផ្លាស់ប្តូរផ្នែកស្ថាប័ននិងជាប្រព័ន្ធ នៅក្នុងវិស័យនៃការងាររបស់ខ្លួន។
- អង្គការសង្គមស៊ីវិល ប្រើយុទ្ធសាស្ត្រផ្សេងៗនៃការងារតស៊ូមតិ រួមមានសម្ពាធប្រជាជន ការជំរុញការយល់ដឹង ការធ្វើចលនាមតិសាធារណៈ ការផ្តល់ឱកាសជំនាញ ការកសាងបណ្តាញ ការបញ្ចុះបញ្ចូល និងវិធីសាស្ត្រដទៃទៀត។
- ជនទាំងឡាយដែលជាគោលដៅ នៃការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល ធ្វើសកម្មភាពលើការតស៊ូមតិនោះ។
- ការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល ផ្តល់លំហរ និងវេទិកាសម្រាប់ឱ្យប្រជាជនផ្សារភ្ជាប់គ្នាក្នុងចំណោមសហគមន៍ ចលនា និងម្ចាស់អំណាច។
- ហានិភ័យសម្រាប់ភាគីពាក់ព័ន្ធដែលចូលរួមក្នុងការងាររបស់អង្គការសង្គមស៊ីវិល ត្រូវបានកាត់បន្ថយ និងផ្សព្វផ្សាយដោយចំហរ។
- ការវាយតម្លៃ ឆ្លុះបញ្ចាំងយោបល់ និងជំហររបស់ប្រជាជនផ្សេងៗច្រើន រួមទាំងអ្នកដែលរងផលប៉ះពាល់ និងអ្នកដែលត្រូវបាននិយាយទៅកាន់ដោយការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូមតិកែលម្អនិងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធ យល់ឃើញថាការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិលផ្តោតលើបញ្ហា និងកង្វល់ទាំងឡាយដែលទាក់ទិននឹងពួកគេ។
- ភាគីពាក់ព័ន្ធ យល់ថាការងាររបស់អង្គការសង្គមស៊ីវិល គាំទ្រពួកគេនៅក្នុងប្រការដែលពួកគេត្រូវបានស្តាប់ឮដោយជនគោលដៅ។
- ភាគីពាក់ព័ន្ធ យល់ថាការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិលទទួលជោគជ័យ ក្នុងការធ្វើឱ្យកង្វល់និងការតស៊ូរបស់ពួកគេត្រូវបានមើលឃើញថាស្របច្បាប់ដោយសាធារណជនដ៏ទូលាយ។
- ភាគីពាក់ព័ន្ធដែលចូលរួមក្នុងការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិលដឹង និងត្រូវបានធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់អំពីហានិភ័យដែលអាចមាន។

- ភាគីពាក់ព័ន្ធដែលចូលរួម ក្នុងការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិលពេញចិត្តនឹងយុទ្ធសាស្ត្រដែលអង្គការប្រើដើម្បីផ្តល់ព័ត៌មានដល់ពួកគេនិងកាត់បន្ថយហានិភ័យរបស់ពួកគេ។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងលទ្ធផលនៃការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល និងពេញចិត្តនឹងការចូលរួមរបស់ពួកគេក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកប្រមូលព័ត៌មាន រៀបចំខ្លឹមសារ និងសម្រេចចិត្តអំពីគោលវិធីនៃកិច្ចប្រឹងប្រែងតស៊ូមតិរបស់អ្នក យ៉ាងដូចម្តេច?
- តើអ្នកធ្វើដូចម្តេចទើបដឹងថាភាគីពាក់ព័ន្ធគាំទ្រការងារតស៊ូមតិរបស់អ្នក និងវាយតម្លៃខ្ពស់ចំពោះឥទ្ធិពលរបស់វា?
- តើអ្នកធានាយ៉ាងដូចម្តេចឱ្យបានប្រាកដថាការងារតស៊ូមតិរបស់អ្នកដោះស្រាយមូលហេតុ ជាឫសគល់ និងព្យាយាមឆ្ពោះទៅកាន់ការផ្លាស់ប្តូរជាប្រព័ន្ធ?
- តើអ្នកសម្រេចតុល្យភាពយុទ្ធសាស្ត្រនៃអភិក្រមដើម្បីផ្លាស់ប្តូរទាំងការងារកម្រិតមូលដ្ឋាន/ការងារលម្អិត និងគោលនយោបាយយ៉ាងដូចម្តេច?
- តើអ្នកកំណត់ហានិភ័យ និងឆ្លើយតបយ៉ាងដូចម្តេចទៅនឹងការគំរាមកំហែងចំពោះប្រជាជនដែលចូលរួមក្នុងការងារតស៊ូមតិ និងយុទ្ធនាការរបស់អ្នក?
- តើអ្នកវាយតម្លៃឥទ្ធិពលនៃការងារតស៊ូមតិរបស់អ្នក និងពិភាក្សាការផ្លាស់ប្តូរជាមួយប្រជាជនដែលអ្នកធ្វើការក្នុងនាមពួកគេទាំងនោះយ៉ាងដូចម្តេច?

# ជំពូកទី២

# គោលវិធីរបស់យើងចំពោះការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៨



# ជំពូកទី២ / គោលវិធីរបស់យើងចំពោះការផ្លាស់ប្តូរ

## គោលការណ៍អនុវត្តទី៨




### អង្គការបើកចំហរ

យើងនឹងមានតម្លាភាពចំពោះកិច្ចការរបស់យើង យើងជាអ្នកណា អ្វីខ្លះជាចំនុចជោគជ័យ និងបរាជ័យរបស់យើង។

អង្គការបើកចំហរ គឺមានតម្លាភាពអំពីការងាររបស់ពួកគេ និងអត្តសញ្ញាណរបស់ពួកគេ។ ពួកគេចែករំលែកព័ត៌មានពាក់ព័ន្ធជាមួយប្រជាជន ដៃគូ និងសាធារណជន ដោយមានការទទួលខុសត្រូវ។ តម្លាភាពនេះ អនុញ្ញាតឱ្យអ្នកដទៃអាចចូលរួមក្នុងការសន្ទនាបែបស្ថាបនា និងចូលរួមនៅក្នុង ការងាររបស់អង្គការ ដូច្នេះអង្គការបើកចំហរអាចរៀនសូត្រ និងកែលម្អ។ អង្គការសង្គមស៊ីវិលដែលតំណាងឱ្យតម្លាភាព មិនត្រឹមតែពង្រឹងការងាររបស់ពួកគេខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងទំនុកចិត្ត និងជំនឿជាក់លើពួកគេ និងវិស័យសង្គមស៊ីវិលជារួម ដែលរួមចំណែកដល់ការការពារលំហរពលរដ្ឋទៀតផង។

### សកម្មភាពគន្លឹះ

៨.១
ចែករំលែកព័ត៌មានអំពីប្រការដែលថាតើយើង គឺជាអ្នកណា តើយើងធ្វើអ្វី និងតើការសម្រេចចិត្តត្រូវបានធ្វើយ៉ាងដូចម្តេច ធនធានដែលយើងមាន និងផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាននៃការងាររបស់យើង។

៨.២
ចែករំលែកព័ត៌មានឱ្យបានទាន់ពេល និងឱ្យបានត្រឹមត្រូវ និងតាមវិធីនានាដែលងាយរកបានសម្រាប់ប្រជាជនទាំងអស់។

៨.៣
បង្កើត និងលើកកម្ពស់នីតិវិធីច្បាស់លាស់នៅក្នុងអង្គការរបស់យើង ដើម្បីគោរពសិទ្ធិឯកជនភាព និងការពារទិន្នន័យផ្ទាល់ខ្លួនពីការប្រើបំពាន។

៨.៤
ផ្តល់កាលានុវត្តភាពសម្រាប់ឱ្យប្រជាជនចោទសួរការងាររបស់យើង និងចូលរួមក្នុងការសន្ទនាក្នុងលក្ខណៈស្ថាបនា ដើម្បីឈានដល់ការយល់ដឹងរួមមួយ តាមដែលអាចធ្វើទៅបាន។

៨.៥
ធានាឱ្យបានប្រាកដថាការប្រាស្រ័យទាក់ទង និងការរកទីផ្សាររបស់យើង ឆ្លុះបញ្ចាំងគុណតម្លៃរបស់យើង និងការពារសេចក្តីថ្លៃថ្នូរ និងឯកជនភាពរបស់ប្រជាជន។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- គោលនយោបាយគន្លឹះរបស់អង្គការសង្គមស៊ីវិល មានចែងពីការប្រាស្រ័យទាក់ទង តម្លាភាព និងការគ្រប់គ្រង និងការចែករំលែកព័ត៌មានដែលស្របតាមល័ក្ខខ័ណ្ឌច្បាប់ក្នុងស្រុក និងដែលត្រូវបានតាមដានយ៉ាងទៀងទាត់។
- អង្គការសង្គមស៊ីវិល ចែករំលែកព័ត៌មានពាក់ព័ន្ធអំពីការងាររបស់ខ្លួន ប្រភពផ្តល់មូលនិធិ និងផលប៉ះពាល់ ដោយប្រើមធ្យោបាយ និងច្រកដែលអាចទទួលបានដោយភាគីពាក់ព័ន្ធទាំងអស់។
- គោលនយោបាយ និងនីតិវិធីច្បាស់លាស់ ដើម្បីការពារទិន្នន័យផ្ទាល់ខ្លួនរួមទាំងគោលនយោបាយ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ ការប្រើការផ្ទេរ និងការទុកដាក់។ គោលនយោបាយ និងនីតិវិធីទាំងនេះ ត្រូវបានគេដឹង និងលើកកម្ពស់ដោយបុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្ត ម្ចាស់ជំនួយ ដៃគូ និងប្រជាជនដែលអង្គការសង្គមស៊ីវិលធ្វើការជាមួយ។
- កាលានុវត្តភាពសម្រាប់ឱ្យប្រជាជនសួរសំណួរ និងចូលរួមជាមួយអង្គការសង្គមស៊ីវិលក្នុងការសន្ទនាបែបស្ថាបនា មានលក្ខណៈផ្សេងៗ និងអាចរកបានសម្រាប់ប្រជាជនទាំងអស់។
- ប្រជាជនចូលរួមក្នុងការសន្ទនាបែបស្ថាបនាជាមួយ អង្គការសង្គមស៊ីវិល អំពីការងាររបស់ខ្លួន។
- អង្គការសង្គមស៊ីវិល មានសេចក្តីចែងច្បាស់នៅក្នុងគោលការណ៍ណែនាំ និងគោលនយោបាយរបស់ខ្លួន អំពីការប្រាស្រ័យទាក់ទងនិងការរកទីផ្សារប្រកបដោយសីលធម៌ ដែលត្រូវបានចែករំលែក និងអនុវត្តតាមប្រកបដោយសង្គតិភាព។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធផ្សេងៗ ដែលមានសេចក្តីត្រូវការផ្សេងៗគ្នា យល់ថាពួកគេមានលទ្ធភាពទាន់ពេល និងសមស្របក្នុង ការទទួលបានព័ត៌មានអំពីការងារ ការផ្តល់មូលនិធិ និងផលប៉ះពាល់របស់អង្គការសង្គមស៊ីវិល។
- បុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្ត ដៃគូ និងប្រជាជនដែលអង្គការសង្គមស៊ីវិលធ្វើការជាមួយដឹងថាតើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច និងថាតើត្រូវគ្រប់គ្រងប្រកបដោយសុវត្ថិភាពនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដទៃ យ៉ាងដូចម្តេច។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងកាលានុវត្តភាពដែលពួកគេមានក្នុងការសួរសំណួរ ពិភាក្សា និងមានឥទ្ធិពលលើការងាររបស់អង្គការសង្គមស៊ីវិល។
- ភាគីពាក់ព័ន្ធ ដឹងពីការអនុវត្តការប្រាស្រ័យទាក់ទង និងការរកទីផ្សាររបស់អង្គការសង្គមស៊ីវិល និងជឿថាអង្គការសង្គមស៊ីវិលគោរពសេចក្តីថ្លៃថ្នូរ និងឯកជនភាពរបស់ពួកគេ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកចែករំលែកព័ត៌មានអំពីអង្គការរបស់អ្នក និងជោគជ័យ និងបរាជ័យរបស់អង្គការអ្នក យ៉ាងដូចម្តេច និងតាមវិធីណា ?
- តើអ្នកធ្វើដូចម្តេចទើបដឹងថាភាគីពាក់ព័ន្ធសំខាន់ៗយល់ថាព័ត៌មាននេះមានលក្ខណៈទាន់ពេលមានប្រយោជន៍ និងអាចរកបាន និងប្រើវាសម្រាប់ផ្តល់មតិកែលម្អ និងការសន្ទនា ?
- តើអ្នកធានាឱ្យបានប្រាកដនូវចម្លើយតបគ្រប់គ្រាន់ចំពោះគំនិត សំណើសុំព័ត៌មាន និងកង្វល់ដែលបានកំណត់ យ៉ាងដូចម្តេច ?
- តើកាលានុវត្តភាពអ្វីខ្លះដែលប្រជាជនមានក្នុងការសួរសំណួរ និងបញ្ចេញទស្សនៈនិងកង្វល់របស់ពួកគេអំពីគោលវិធី សកម្មភាព បុគ្គលិក និងផលប៉ះពាល់របស់អង្គការអ្នក ?
- តើអ្នកការពារសេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពរបស់ភាគីពាក់ព័ន្ធដែលអាចស្ថិតក្នុងគ្រោះថ្នាក់ តាមរយៈការអនុវត្តការប្រាស្រ័យទាក់ទង និងការរកទីផ្សាររបស់អ្នកយ៉ាងដូចម្តេច និងតើអ្នកកាត់បន្ថយចំណុចនេះរបៀបណា ?

# ជំពូកទី៣

# អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី៩

៩



បុគ្គលិកនិងអ្នកស្ម័គ្រចិត្ត
ប្រកបដោយភាពអង់អាច
និងប្រសិទ្ធភាព

# ជំពូកទី៣ / អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី៩




### បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តប្រកបដោយភាពអង់អាច និងប្រសិទ្ធភាព

យើង នឹងវិនិយោគលើបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តដើម្បីអភិវឌ្ឍសក្តានុពលពេញលេញរបស់ពួកគេ និងដើម្បីសម្រេចគោលបំណងរបស់យើង ។

អង្គការមានប្រសិទ្ធភាព គឺមានបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តដែលមានគុណវុឌ្ឍ និងការតាំងចិត្តខ្ពស់ អ្នកដែលមានទឹកចិត្ត និងសមត្ថភាពវិជ្ជាជីវៈ ក្នុងការជំរុញកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាព និងសម្រេចគោលបំណងរួម។ បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តប្រកបដោយវិជ្ជាជីវៈមានធនធានគ្រប់គ្រាន់ និងបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តមាន ភក្តីភាពកែលម្អគុណភាពការងាររបស់អង្គការមួយ និងកាត់បន្ថយហានិភ័យនៃការគ្រប់គ្រងមិនបានល្អ។ ដើម្បីសម្រេចចំណុចនេះ អង្គការសង្គមស៊ីវិល ត្រូវតែមានគោលការណ៍ គោលនយោបាយ និងនីតិវិធីប្រកបដោយតម្លាភាព និងត្រឹមត្រូវសម្រាប់ការជ្រើសរើស ការអភិវឌ្ឍ និងការគ្រប់គ្រងបុគ្គលិក។ ដោយដាក់បញ្ចូលបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត នៅក្នុងកិច្ចដំណើរការរៀបចំផែនការ និងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត អង្គការសង្គមស៊ីវិល នឹងបង្កើតបរិយាកាសផ្តល់ភាពអង់អាច ដែលនៅក្នុងនោះ បុគ្គលអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងល្អតលាស់។

### សកម្មភាពគន្លឹះ

៩.១
ធានាឱ្យបានប្រាកដថាបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តចែករំលែក និងធ្វើសកម្មភាពស្របតាមគុណតម្លៃ និងបទដ្ឋានវិជ្ជាជីវៈរបស់យើង។

៩.២
មានវិធីជ្រើសរើសបុគ្គលិក និងការអនុវត្តការងារដែលមានលក្ខណៈត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងគុណតម្លៃផ្សេងៗគ្នា។

៩.៣
លើកទឹកចិត្តបុគ្គលិកនិងអ្នកធ្វើការស្ម័គ្រចិត្តឱ្យកែលម្អជាប្រចាំនូវជំនាញរបស់ពួកគេ និងផ្តល់ជូនពួកគេនូវធនធានដែលពួកគេត្រូវការដើម្បីធ្វើកិច្ចការនេះ។

៩.៤
ពាក់ព័ន្ធបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តនៅគ្រប់កម្រិត នៃអង្គការរបស់យើង នៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់យើង និងជំរុញភាពជាអ្នកដឹកនាំ។

៩.៥
ការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ប្រជាជន ដែលធ្វើការជាមួយពួកយើង និងបង្កើតកន្លែងធ្វើការដែលមានលក្ខណៈយុត្តិធម៌និងគាំទ្រ។

## កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- គុណតម្លៃ បទដ្ឋាន និងអាណត្តិរបស់អង្គការសង្គមស៊ីវិល ត្រូវបានដឹងច្បាស់ក្នុងចំណោមបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត ហើយក្រមប្រតិបត្តិមួយចែងយ៉ាងច្បាស់អ្វីដែលត្រូវបានរំពឹងពីពួកគេ។
- កិច្ចដំណើរការជួលរបស់អង្គការសង្គមស៊ីវិលមានលក្ខណៈត្រឹមត្រូវ និងប្រកបដោយតម្លាភាព។
- គោលនយោបាយផ្ទៃក្នុង រចនាសម្ព័ន្ធ និងកិច្ចដំណើរការរបស់អង្គការសង្គមស៊ីវិល គិតពីសេចក្តីត្រូវការជាក់លាក់របស់ស្ត្រី និងក្រុមជនភាគតិច។
- អង្គការសង្គមស៊ីវិល លើកស្ទួយសិទ្ធិការងារ និងផ្តល់បរិយាកាសការងារមួយដែលមានលក្ខណៈត្រឹមត្រូវគាំទ្រ សម្រាប់ទាំងអស់គ្នា បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត។
- អង្គការសង្គមស៊ីវិល មានគោលការណ៍ណែនាំច្បាស់លាស់ និងធនធានសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ដែលត្រូវបានដឹងដោយបុគ្គលិកនិងអ្នកធ្វើការស្ម័គ្រចិត្ត និងដែលត្រូវបានអនុវត្តដោយគណគ្រប់គ្រង។
- អង្គការសង្គមស៊ីវិល មានរចនាសម្ព័ន្ធការងារ និងកិច្ចដំណើរការបង្ហឹកការងារ ដើម្បីគាំទ្របុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តទាំងអស់ក្នុងការអភិវឌ្ឍសក្តានុពលវិជ្ជាជីវៈរបស់ពួកគេ។
- អង្គការសង្គមស៊ីវិល វាយតម្លៃយ៉ាងទៀងទាត់នូវស្នាដៃការងារ តម្រូវការធនធានមនុស្ស និង ការអភិវឌ្ឍគណដឹកនាំអនាគត និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់នូវកិច្ចពិពណ៌នាការងារ ការទទួលខុសត្រូវ និងគោលដៅ។
- អង្គការសង្គមស៊ីវិល មានគោលនយោបាយនិងនីតិវិធីច្បាស់លាស់ដែលកំណត់កិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតផ្សេងៗនិងប្រគល់ការទទួលខុសត្រូវ។
- អង្គការសង្គមស៊ីវិល ទទួលស្គាល់ករណីយកិច្ចថែទាំរបស់ខ្លួន និងមានគោលនយោបាយនិងគោលការណ៍ណែនាំ ស្តីពីសន្តិសុខដែលមានលក្ខណៈជាក់លាក់តាមទីកន្លែង ដែលត្រូវបានដឹង និងត្រូវបានអនុវត្តដោយបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត។
- អង្គការសង្គមស៊ីវិល មានយន្តការនិងកិច្ចព្រមព្រៀងសម្រាប់វិភាគ និងចែករំលែកព័ត៌មានស្តីពីហានិភ័យសន្តិសុខនានា ដែលប៉ះពាល់ពួកគេខ្លួនឯង និងសហគមន៍នៅក្នុងតំបន់ការងាររបស់ពួកគេ។

## មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធ យល់ឃើញថាអាកប្បកិរិយា និងឥរិយាបថរបស់បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត

នៃអង្គការសង្គមស៊ីវិល មានលក្ខណៈវិជ្ជាជីវៈនិង ពោរពេញដោយក្តីគោរព។

- ភាគីពាក់ព័ន្ធរីករាយជាមួយអង្គការសង្គមស៊ីវិល ដោយមាននិយោជកមានភាពបើកចំហរ។
- បុគ្គលិកយល់ឃើញថាពួកគេបានទទួលការគិតគូ យកចិត្តទុកដាក់យ៉ាងត្រឹមត្រូវ ហើយថាអង្គការសង្គមស៊ីវិលគោរពសិទ្ធិការងាររបស់ពួកគេ។
- បុគ្គលិកយល់ដឹងពីគោលការណ៍អនុវត្តរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍសមត្ថភាព ការទទួលខុសត្រូវ និងសក្តានុពលផ្នែកវិជ្ជាជីវៈរបស់ពួកគេ។
- បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តយល់ថាស្នាដៃការងាររបស់ពួកគេត្រូវបានទទួលស្គាល់ ត្រូវបានវាយតម្លៃប្រកបដោយយុត្តិធម៌ និងត្រូវបានកែលម្អ ដោយអង្គការសង្គមស៊ីវិល។
- បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តរបស់អង្គការសង្គមស៊ីវិលយល់ថាពួកគេចូលរួមបានគ្រប់គ្រាន់ក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត។
- បុគ្គលិកនិងអ្នកធ្វើការស្ម័គ្រចិត្ត គិតថាកន្លែងធ្វើការរបស់ពួកគេមានសុវត្ថិភាព យុត្តិធម៌ និងមានលក្ខណៈគាំទ្រ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកធានាយ៉ាងដូចម្តេចឱ្យបានប្រាកដថាគុណតម្លៃ ក្រមប្រតិបត្តិ បទដ្ឋានអាកប្បកិរិយានិងឥរិយាបថរំពឹងទុកនៃអង្គការរបស់អ្នក ត្រូវបានគេដឹងនិងគោរពអនុវត្ត?
- តើអង្គការរបស់អ្នកលើកកម្ពស់នូវភាពផ្សេងគ្នា និងពិចារណាលក្ខណៈពិសេសអ្វីខ្លះចំពោះសេចក្តីត្រូវការរបស់ស្ត្រី និងក្រុមជនភាគតិចដែលធ្វើការជូនឬជាមួយអ្នក?
- តើអ្នកវាយតម្លៃស្នាដៃការងារ និងតម្រូវការអភិវឌ្ឍជំនាញ និងសមត្ថភាពការងារនៃបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តរបស់អ្នកដើម្បីធ្វើការងាររបស់ពួកគេឱ្យបានកាន់តែប្រសើរឡើង យ៉ាងដូចម្តេច?
- តើអ្នកពាក់ព័ន្ធបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តផ្សេងៗ នៅក្នុងកិច្ចដំណើរការរៀបចំផែនការនិងធ្វើសេចក្តីសម្រេចចិត្ត យ៉ាងដូចម្តេច និងតើអ្នកគាំទ្រពួកគេយ៉ាងដូចម្តេច នៅក្នុងមហិច្ឆតានៃសក្តានុពលជាអ្នកដឹកនាំ?
- តើមានយន្តការអ្វីខ្លះសម្រាប់ឱ្យបុគ្គលិកសម្តែងកង្វល់និងគំនិតរបស់ពួកគេ តាមវិធីមួយដែលគ្មានផលវិបាកអវិជ្ជមាន?
- តើអ្នកធ្វើដូចម្តេចទើបដឹងថាកិច្ចប្រឹងប្រែងរបស់អ្នកក្នុងការបង្កើតបរិស្ថាន មួយប្រកបដោយសុវត្ថិភាព មានយុត្តិធម៌ និងមានលក្ខណៈគាំទ្រទទួលបានជោគជ័យរួមទាំងនៅក្នុងតំបន់មានវិវាទ និងតំបន់មានហានិភ័យខ្ពស់?

# ជំពូកទី៣

# អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១០



# ជំពូកទី៣ / អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១០




### ធនធានចាត់ចែងបានល្អ

យើងនឹងចាត់ចែងធនធានរបស់យើង ប្រកបដោយការទទួលខុសត្រូវ ដើម្បីសម្រេចគោលបំណងរបស់យើង និងបម្រើផលប្រយោជន៍សាធារណៈ។

ការប្រើប្រាស់ប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និងសីលធម៌នូវធនធានហិរញ្ញវត្ថុ និងធនធានដទៃទៀត គឺមានលក្ខណៈសំខាន់ក្រៃលែង សម្រាប់ឱ្យអង្គការសង្គមស៊ីវិលគ្រប់គ្រងកម្មវិធី សម្រេចលទ្ធផល និងដើម្បីអភិវឌ្ឍព្រមទាំង កសាងទំនុកចិត្តពីភាគីពាក់ព័ន្ធ។ ការគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំ តម្រូវឱ្យអង្គការធ្វើលទ្ធកម្មធនធានរបស់ពួកគេ ប្រកបដោយសីលធម៌ និងប្រើធនធានទាំងនោះតាមវិធីមួយដែលឆ្លុះបញ្ចាំងគុណតម្លៃរបស់ពួកគេ សម្រេចគោលដៅរបស់ពួកគេ ជៀសវាងការខ្ជះខ្ជាយ និងរួមចំណែកដល់ការផ្លាស់ប្តូរវិជ្ជមានជាប់លាប់។ ហេតុដូច្នេះ អង្គការសង្គមស៊ីវិលត្រូវតែប្រកាន់ខ្ជាប់នូវបទដ្ឋានគណនេយ្យហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ជាទូទៅធានាឱ្យបានប្រាកដនូវការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដ៏ម៉ត់ចត់ និងកាត់បន្ថយ ហានិភ័យនៃការប្រើមូលនិធិខុស ដោយចាត់ចែងធនធាន ប្រកបដោយការទទួលខុសត្រូវ ស្របតាមបេសកកម្មរបស់ពួកគេ និងសម្រាប់គោលបំណងចង់បានរបស់ពួកគេ។

### សកម្មភាពគន្លឹះ

១០.១
ធ្វើលទ្ធកម្មធនធានតាមវិធីនានាដែលមានលក្ខណៈស្របនឹងគុណតម្លៃ ឯករាជ្យភាព និងគោលបំណងរបស់យើង។

១០.២
គ្រប់គ្រងធនធានប្រកបដោយការទទួលខុសត្រូវ ប្រើប្រាស់ធនធានស្របតាមគោលបំណង និងតាមវិធីនានាដែលបង្កើនជាអតិបរមានូវផលប៉ះពាល់។

១០.៣
គោរពតាមបទដ្ឋានវិជ្ជាជីវៈគណនេយ្យ និង ធានាឱ្យបានប្រាកដនូវការគ្រប់គ្រងហិរញ្ញវត្ថុដ៏ម៉ត់ចត់ ដើម្បីកាត់បន្ថយហានិភ័យនៃការពុករលួយ សំណូក ការប្រើមូលនិធិខុស និងទំនាស់ផលប្រយោជន៍។

១០.៤
រាយការណ៍ដោយចំហរនិងដោយមានតម្លាភាពទៅកាន់អ្នកដែលផ្តល់ធនធានឱ្យយើង និងអំពីរបៀបដែលយើងគ្រប់គ្រងធនធាន។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល មានគោលការណ៍ណែនាំ និងនីតិវិធីប្រកបដោយប្រសិទ្ធភាព សម្រាប់ការកៀរគរមូលនិធិ លទ្ធកម្ម និងការប្រើប្រាស់និងការគ្រប់គ្រងធនធានប្រកបដោយសីលធម៌ ជាមួយបទប្បញ្ញត្តិសម្រាប់៖ ការកៀរគរ និងវិភាជន៍មូលនិធិ និងភាគទានមិនមែនជាហិរញ្ញវត្ថុ ការទប់ស្កាត់ការក្លែងបន្លំ ការសង្ស័យពីការដែលអាចនាំឱ្យមានអំពើពុករលួយ ការប្រើធនធានមិនត្រឹមត្រូវ និងទំនាស់ផលប្រយោជន៍។
- មូលនិធិត្រូវបានប្រើស្របតាមផែនការថវិកា និងសម្រាប់គោលបំណងដែលបានរៀបចំទុកដើម្បីសម្រេចបានគោលបំណងជាយុទ្ធសាស្ត្ររបស់អង្គការសង្គមស៊ីវិល។
- ចំណាយត្រូវបានតាមដានយ៉ាងទៀងទាត់ ការធ្វើសវនកម្មហិរញ្ញវត្ថុដោយក្រុមឯករាជ្យដោយប្រើបទដ្ឋានគណនេយ្យ ត្រូវបានធ្វើ ហើយលទ្ធផលរបាយការណ៍សវនកម្មបានប្រាប់ទៅ ដល់បុគ្គលិកពាក់ព័ន្ធ ហើយអនុសាសន៍របស់សវនករត្រូវបានអនុវត្តតាម។
- ការទិញទំនិញនិងសេវា គោរពតាមកិច្ចដំណើរការដេញថ្លៃប្រកបដោយការប្រកួតប្រជែង និងតម្លាភាព។
- ព័ត៌មានអំពីប្រភព និងវិភាជន៍នៃមូលនិធិរបស់អង្គការសង្គមស៊ីវិល ត្រូវបានចែករំលែកដោយចំហរ របាយការណ៍ និងឯកសារអាចរកមើលផ្ទៀងផ្ទាត់បាន។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូមតិកែលម្អនិងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធជឿថាអង្គការសង្គមស៊ីវិលគ្រប់គ្រងធនធានរបស់អង្គការ ដោយមានការទទួលខុសត្រូវ។
- ភាគីពាក់ព័ន្ធ ជឿថាអង្គការសង្គមស៊ីវិលប្រើប្រាស់ធនធានរបស់ខ្លួនបានល្អបំផុត ដើម្បីបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីសម្រេចផលប៉ះពាល់ដែលអាចមានឱ្យបានច្រើនបំផុត។
- អ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវា យល់ថាកិច្ចដំណើរការដេញថ្លៃរបស់អង្គការសង្គមស៊ីវិល គឺត្រឹមត្រូវ និងមានតម្លាភាព។
- ភាគីពាក់ព័ន្ធ ពេញចិត្តនឹងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានព័ត៌មានអំពីប្រភពនិងវិភាជន៍នៃធនធានរបស់អង្គការសង្គមស៊ីវិល។
- បុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្តរបស់អង្គការសង្គមស៊ីវិល និងប្រជាជនដែលពួកគេធ្វើការជាមួយ ដឹងពីវិធីមានសុវត្ថិភាពសម្រាប់រាយការណ៍អំពីការក្លែងបន្លំ និងសំណូក។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើអ្នកធានាយ៉ាងដូចម្ដេចឱ្យបានប្រាកដថា យុទ្ធសាស្ត្រកៀរគរមូលនិធិរបស់អ្នក មានលក្ខណៈស្របគ្នាទៅនឹងការប្រតិបត្តិប្រកបដោយសីលធម៌ និងបេសកកម្ម និងគុណតម្លៃនៃអង្គការរបស់អ្នក?
- តើអ្នកមានកិច្ចដំណើរការ និងការគ្រប់គ្រងការធ្វើសេចក្ដីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុអ្វីខ្លះ ដើម្បីធានាឱ្យបានប្រាកដថា ការក្លែងបន្លំ ការពុករលួយ សំណូក និងអំពើមិនប្រពៃផ្នែកហិរញ្ញវត្ថុដទៃទៀត ត្រូវបានទប់ស្កាត់ និងថាអ្នកដែលប្រើមូលនិធិខុសតម្រូវឱ្យទទួលខុសត្រូវ?
- តើអ្នកធានាយ៉ាងដូចម្ដេច ឱ្យបានប្រាកដថា ធនធានរបស់អ្នកត្រូវបានវិភាជន៍បានល្អបំផុត ដើម្បីជំរុញប្រកបដោយប្រសិទ្ធភាពបំផុតនូវផលប៉ះពាល់ប្រកបដោយចីរភាពដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការ និងអាទិភាពជាក់ស្ដែងរបស់ប្រជាជន?
- តើអ្នកមាននីតិវិធីអ្វីខ្លះដើម្បីការពារអ្នករាយការណ៍ និងអ្នកដែលរាយការណ៍អំពីការប្រើមូលនិធិខុស?
- តើអ្នកផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអ្វីខ្លះ អំពីប្រភព និងវិភាជន៍មូលនិធិរបស់អ្នក និងផ្សព្វផ្សាយយ៉ាងដូចម្ដេច?
- តើអ្នកធ្វើដូចម្ដេចដើម្បីទទួលបានធនធាន ស្របតាមគុណតម្លៃរបស់អ្នក និងដោយមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពនៃអង្គការរបស់អ្នក?

# ជំពូកទី៣

# អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១១



# ជំពូកទី៣ / អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១១

១១

ការធ្វើសេចក្តីសម្រេចចិត្តបែបឆ្លើយតប

ការធ្វើសេចក្តីសម្រេចចិត្តបែបឆ្លើយតប តម្រូវឱ្យអង្គការបើកទូលាយចំពោះការស្នើសុំ និងការឆ្លើយតបទៅនឹងមតិកែលម្អ។ ប្រព័ន្ធផ្តល់មតិកែលម្អមានប្រសិទ្ធភាពមួយ នឹងជួយអង្គការសង្គមស៊ីវិលក្នុងការកែលម្អទាំងកម្មវិធី ទាំងស្នាដៃការងាររបស់អង្គការ។ វាក៏អាចជួយផងដែរក្នុងការធ្វើឱ្យភាគីពាក់ព័ន្ធចូលរួមបង្កើតរួមគ្នា និងពន្យល់បង្ហាញពីគណនេយ្យភាពទៅកាន់ភាគីពាក់ព័ន្ធ។ មិនត្រឹមតែប្រមូលមតិកែលម្អតែប៉ុណ្ណោះទេ អង្គការសង្គមស៊ីវិលត្រូវតែ បើកចំហរ និងមានឆន្ទៈប្រើមតិកែលម្អក្នុងលក្ខណៈស្ថាបនា ដើម្បីឆ្លុះបញ្ចាំងអំពីការប្រតិបត្តិរបស់ពួកគេ និងឆ្លើយតបដោយធ្វើការផ្លាស់ប្តូរចាំបាច់នានា។ អង្គការសង្គមស៊ីវិល ក៏គប្បីបិទបញ្ចប់មតិកែលម្អផងដែរ តាមរយៈការពិភាក្សា និងស្វែងរកដំណោះស្រាយ ជាមួយដៃគូបុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត និងសំខាន់បំផុត ជាមួយប្រជាជនដែលពួកគេធ្វើការជាមួយ។

### ការធ្វើសេចក្តីសម្រេចចិត្តបែបឆ្លើយតប

**យើងនឹង ធានាឱ្យបានប្រាកដថាការសម្រេចចិត្តរបស់យើងមានលក្ខណៈឆ្លើយតបទៅនឹងមតិកែលម្អពីប្រជាជនដែលរងផលប៉ះពាល់ពីការងារ ដៃគូអ្នកធ្វើការស្ម័គ្រចិត្ត និងបុគ្គលិករបស់យើង។**

---

### សកម្មភាពគន្លឹះ

១១.១

បើកឱ្យមាន និងវិភាគមតិកែលម្អ និងបណ្តឹងពីក្រុម ភាគីពាក់ព័ន្ធសំខាន់ៗដើម្បីផ្តល់ព័ត៌មានដល់ការធ្វើសេចក្តីសម្រេចចិត្ត។

១១.២

ធានាឱ្យបានប្រាកដថាកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត បានទទួលព័ត៌មានពី និងមានលក្ខណៈឆ្លើយតបទៅនឹងមតិកែលម្អពីភាគីពាក់ព័ន្ធរបស់យើង ជាពិសេសពីប្រជាជនដែលរងផលប៉ះពាល់ពីការងាររបស់យើង។

១១.៣

បំភ្លឺ និងផ្សព្វផ្សាយអំពីរបៀបដែលប្រជាជនអាចផ្តល់ ធាតុចូលនិងមតិកែលម្អទៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

១១.៤

អនុញ្ញាតឱ្យបុគ្គលិកជួរមុខ និងអ្នកធ្វើការស្ម័គ្រចិត្តអាចឆ្លើយតបទៅនឹងមតិកែលម្អ និងធ្វើការសម្រេចចិត្ត តាមពេលវេលាជាក់ស្តែង។

១១.៥

ផ្សព្វផ្សាយអំពីមតិកែលម្អដែលបានទទួល របៀបដែលមតិកែលម្អត្រូវបានប្រើ និងការផ្លាស់ប្តូរអ្វីខ្លះដែលត្រូវបានធ្វើ។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និងរចនាសម្ព័ន្ធ

ភស្តុតាងនានា ដូចជា ការសិក្សាវាយតម្លៃ ការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល មានកិច្ចដំណើរការទទួលមតិកែលម្អ និងបណ្តឹងដែលឆ្លុះបញ្ចាំងបេសកកម្ម សមត្ថភាព និងបរិបទរបស់អង្គការ។
- អង្គការសង្គមស៊ីវិល អភិវឌ្ឍ ប្រើ និងផ្សព្វផ្សាយឧបករណ៍ និងយន្តការសមស្របសម្រាប់ឱ្យភាគីពាក់ព័ន្ធផ្តល់មតិកែលម្អ។
- អង្គការសង្គមស៊ីវិល ស្នើសុំ ផ្តល់តម្លៃ និងវិភាគមតិកែលម្អ យ៉ាងសកម្ម។
- កិច្ចដំណើរការទទួលមតិកែលម្អរបស់អង្គការសង្គមស៊ីវិល រួមមានវិធីនានាសម្រាប់ពិភាក្សាដំណោះស្រាយដែលបានស្នើឡើងនិងប្រាប់ពីសកម្មភាពដែលត្រូវធ្វើ ដល់អ្នកដែលបានផ្តល់មតិកែលម្អ។
- អង្គការសង្គមស៊ីវិល ពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធយ៉ាងសកម្មក្នុងការសម្រេចចិត្ត និងការផ្លាស់ប្តូរកម្មវិធីរបស់ខ្លួន។
- អង្គការសង្គមស៊ីវិល មានប្រតិកម្មទៅនឹងមតិកែលម្អបានទាន់ពេល និងបានត្រឹមត្រូវ ហើយមតិកែលម្អត្រូវបានចាត់ចែងដោយបុគ្គលិកសមស្របបំផុតនៅក្នុងអង្គការ។
- ព័ត៌មានអំពីមធ្យោបាយផ្តល់មតិកែលម្អ និងបណ្តឹងត្រូវបានផ្តល់ជូន និងត្រូវបានយល់ដោយភាគីពាក់ព័ន្ធ បុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្តទាំងអស់ និងប្រជាជនដែលរងផលប៉ះពាល់ពីការងាររបស់អង្គការសង្គមស៊ីវិល។
- បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត ចេះចាត់ចែងមតិកែលម្អ និងបណ្តឹង។
- មាននីតិវិធីដើម្បីធានាឱ្យបានប្រាកដថា អត្តសញ្ញាណរបស់អ្នកប្តឹងត្រូវបានរក្សា ជាការសម្ងាត់។
- គោលការណ៍ និងសេចក្តីណែនាំសម្រាប់ចែករំលែកការ ទទួលខុសត្រូវលើការសម្រេចចិត្តសម្រាប់គ្រប់មតិកែលម្អ មានចែងនៅក្នុងឯកសារយុទ្ធសាស្ត្រ កិច្ចសន្យាបុគ្គលិក និងគោលនយោបាយអភិវឌ្ឍន៍។
- អង្គការសង្គមស៊ីវិល វាយតម្លៃកិច្ចដំណើរការផ្តល់មតិកែលម្អរបស់ខ្លួន និងផលប៉ះពាល់នៃការផ្លាស់ប្តូរដែលត្រូវបានធ្វើ ជាការឆ្លើយតបទៅនឹងមតិកែលម្អដែលបានទទួល។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ភាគីពាក់ព័ន្ធ ជឿថាបទពិសោធន៍ និងយោបល់របស់ពួកគេ ត្រូវបានស្នើសុំ និងផ្តល់តម្លៃយ៉ាងសកម្ម នៅក្នុងការសម្រេចចិត្តផ្នែកកម្មវិធីរបស់អង្គការសង្គមស៊ីវិល។
- ភាគីពាក់ព័ន្ធ ដឹងអំពីយន្តការផ្តល់មតិកែលម្អនិងបណ្តឹងដែលមាន និងយល់ថាមានសុវត្ថិភាពក្នុងការប្រើយន្តការទាំងនោះ។

- ភាគីពាក់ព័ន្ធ ជឿថាមតិកែលម្អ និងបណ្ដឹងរបស់ពួកគេ ត្រូវបានគេចាត់ការទាន់ពេល និងយ៉ាងត្រឹមត្រូវ។
- ភាគីពាក់ព័ន្ធ ចង់ផ្ដល់មតិកែលម្អ និងចូលរួមក្នុងការពិភាក្សាអំពីសកម្មភាពកែតម្រូវ ទាំងឡាយដែលអាចមាន។
- ភាគីពាក់ព័ន្ធ ជឿថាមតិកែលម្អនិងបណ្ដឹងរបស់ពួកគេ ត្រូវបានគេឮ និងពេញចិត្តនឹងរបៀបដែលអង្គការសង្គមស៊ីវិលឆ្លើយតប។
- បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត យល់ថាមានសមត្ថភាពការងារ និងទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិល នៅក្នុងការចាត់ចែងមតិកែលម្អ និងបណ្ដឹង។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើការសម្រេចចិត្តប្រភេទអ្វីខ្លះដែលបើកចំហរចំពោះមតិកែលម្អ និងការបែងចែកការទទួលខុសត្រូវគ្នា ?
- តើអ្នកធ្វើដូចម្ដេចដើម្បីធានាឱ្យបានប្រាកដនូវកិច្ចដំណើរការរយៈពេលវែង ការប្រតិបត្តិ និងវប្បធម៌នៃការធ្វើសេចក្ដីសម្រេចចិត្ត ដែលមានលក្ខណៈឆ្លើយតបទៅនឹងមតិកែលម្អនៅក្នុងអង្គការរបស់អ្នក ?
- តើអ្នកធ្វើដូចម្ដេចដើម្បីធានាឱ្យបានប្រាកដថាប្រជាជនដែលរងផលប៉ះពាល់ពីការងាររបស់អ្នកដឹងអំពីរបៀប ផ្ដល់និងពិភាក្សាមតិកែលម្អ និងបណ្ដឹង ?
- តើគណគ្រប់គ្រង និងគណដឹកនាំកំពុងគាំទ្រ និងរួមបញ្ចូលបុគ្គលិកជួរមុខ និងអ្នកធ្វើការស្ម័គ្រចិត្តនៅមូលដ្ឋានក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងឆ្លើយតបទៅមតិកែលម្អនិងបណ្ដឹង យ៉ាងដូចម្ដេច ?
- តើអ្នករាយការណ៍ត្រឡប់ទៅកាន់អ្នកដែលបានផ្ដល់មតិកែលម្អដំបូង យ៉ាងដូចម្ដេច ?
- តើប្រជាជនមានលទ្ធភាពអ្វីខ្លះសម្រាប់ការចូលរួមក្រោយពេលដែលពួកគេផ្ដល់មតិកែលម្អជូនអ្នក ឬ ដាក់បណ្ដឹង ?

# ជំពូកទី៣

# អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១២



# ជំពូកទី៣ / អ្វីដែលយើងធ្វើនៅផ្ទៃក្នុង

## គោលការណ៍អនុវត្តទី១២

១២

គណៈដឹកនាំមាន
ការទទួលខុសត្រូវ

គណៈដឹកនាំទទួលខុសត្រូវនៃអង្គការមួយ គប្បីមានការចូលរួមដោយអង្គភាពគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលឯករាជ្យមួយ។ អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ពោលគឺ ការគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់ អនុលោមតាមគោលនយោបាយ ការគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព សម្រាប់បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត គឺមានសារៈសំខាន់ក្រៃលែង ប៉ុន្តែ វាគ្រាន់តែជាចំនុចមួយក្នុងមុខនាទីជាអ្នកដឹកនាំតែប៉ុណ្ណោះ។ វាក៏ជាប្រការចាំបាច់ផងដែរដែលគណៈដឹកនាំអង្គការសង្គមស៊ីវិលត្រូវមានចក្ខុវិស័យច្បាស់លាស់មួយ និងគុណតម្លៃប្រកបដោយសីលធម៌សម្រាប់អង្គការ ដើម្បីធ្វើឱ្យអង្គការអាចសម្រេចកិច្ចការប្រកបដោយប្រសិទ្ធភាពសម្រេចតាមគោលបំណង និងអាណត្តិរបស់ខ្លួន។

### គណៈដឹកនាំមានការទទួលខុសត្រូវ

**យើងនឹងធានាឱ្យបានប្រាកដថាអង្គភាពគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់យើងមានគណនេយ្យភាព។**

### សកម្មភាពគន្លឹះ

១២.១
ធានាឱ្យបានប្រាកដថាក្រុមប្រឹក្សាភិបាលឯករាជ្យមួយត្រួតពិនិត្យទិសដៅយុទ្ធសាស្ត្រ ការអនុលោមតាមច្បាប់ ការគ្រប់គ្រងហានិភ័យ និងស្នាដៃការងាររបស់យើង។

១២.២
តម្រូវឱ្យក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងមានគណនេយ្យភាពស្មើគ្នា សម្រាប់ការសម្រេចគោលបំណងជាយុទ្ធសាស្ត្ររបស់យើង និងការបំពេញតាមគោលការណ៍អនុវត្តនានាក្នុងបទដ្ឋាននេះ។

១២.៣
បណ្ដុះវប្បធម៌ទទួលខុសត្រូវ ដែលនៅក្នុងនោះបុគ្គលិកនិងអ្នកធ្វើការស្ម័គ្រចិត្តទាំងអស់ មានការទទួលខុសត្រូវខ្ពស់ចំពោះគណនេយ្យភាពសម្រាប់សកម្មភាព និងផលប៉ះពាល់របស់ពួកគេ។

១២.៤
គាំទ្រភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត ដែលមានការទទួលខុសត្រូវ ចក្ខុវិស័យ និងគំនិតច្នៃប្រឌិត។

១២.៥
ឆ្លើយតបទៅនឹងបណ្ដឹង និងជម្លោះខាងក្នុង និងខាងក្រៅយ៉ាងម៉ឺងម៉ាត់ ដោយបង្កើតលំហរមានសុវត្ថិភាព និងយន្តការសមស្របដើម្បីដោះស្រាយបណ្ដឹង និងជម្លោះទាំងនោះ។

## សូចនាករវឌ្ឍនភាពដែលអាចមានឆ្ពោះទៅកាន់ការបំពេញគោលការណ៍អនុវត្ត

### កិច្ចដំណើរការ គោលនយោបាយ និង រចនាសម្ព័ន្ធ

ភស្តុតាងនានាដូចជាការសិក្សាវាយតម្លៃការរៀបចំផែនការ របាយការណ៍តាមដាន និងវាយតម្លៃ សេចក្តីថ្លែងការណ៍នៃគោលនយោបាយ កិច្ចព្រមព្រៀងដៃគូ ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- អង្គការសង្គមស៊ីវិល មានក្រុមប្រឹក្សាភិបាលឯករាជ្យនិងប្រកបដោយប្រសិទ្ធភាព ជាមួយកិច្ចពិព័ណ៌នាការងារច្បាស់លាស់ ដើម្បីត្រួតពិនិត្យការគ្រប់គ្រង ការទទួលខុសត្រូវលើការផ្តល់ទំនុកចិត្តរបស់អង្គការ និងការបំពេញតាមចក្ខុវិស័យនិងបេសកកម្មរបស់អង្គការ។
- អង្គការសង្គមស៊ីវិល ពិនិត្យមើលយ៉ាងទៀងទាត់នូវទំនាស់ផលប្រយោជន៍ដែលអាចមានទាក់ទិននឹងទំនាក់ទំនងផ្នែកនយោបាយ សេដ្ឋកិច្ច និងផ្ទាល់ខ្លួននៃក្រុមប្រឹក្សាភិបាលរបស់ខ្លួន។
- គណៈដឹកនាំរបស់អង្គការសង្គមស៊ីវិល ធានាឱ្យបានប្រាកដថាគោលនយោបាយ រចនាសម្ព័ន្ធ និងវប្បធម៌អង្គការគាំទ្រការអនុវត្តបទដ្ឋានសកលនេះ។
- គណៈដឹកនាំនៃអង្គការសង្គមស៊ីវិលមានការយល់ដឹងអំពីគណនេយ្យភាព និងប្រើមតិកែលម្អប្រកបដោយប្រសិទ្ធភាព ក្នុងអង្គការនៅគ្រប់កម្រិត។
- គណៈដឹកនាំនៃអង្គការសង្គមស៊ីវិលធានាអនុលោមតាមសេចក្តីតម្រូវ និងអនុសាសន៍របស់ម្ចាស់ជំនួយ និងថាគណៈគ្រប់គ្រងរបស់អង្គការគោរពតាមវិធាននិងច្បាប់ទាំងឡាយដែលរៀបចំដោយរាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត។
- ការរៀនសូត្រដែលទទួលបានពីការតាមដានការវាយតម្លៃ មតិកែលម្អ បណ្តឹង និងធាតុចូលដទៃទៀត ត្រូវបានប្រើដើម្បីផ្តល់ព័ត៌មានដល់ការត្រួតពិនិត្យកែសម្រួលយុទ្ធសាស្ត្រ និងកម្មវិធី។
- បណ្តឹងនិងជម្លោះ ត្រូវបានចាត់ចែងយ៉ាងសមស្រប ស៊ើបអង្កេត និងដោះស្រាយ ហើយដំណោះស្រាយត្រូវបានផ្សព្វផ្សាយជូនដល់អ្នកពាក់ព័ន្ធ។
- អង្គការសង្គមស៊ីវិល មានផែនការបន្តវេន ដើម្បីធានាឱ្យបានប្រាកដថាអង្គការសង្គមស៊ីវិលមានបុគ្គលិកប្រកបដោយសមត្ថភាពដើម្បីទទួលយកការទទួលខុសត្រូវនាអនាគត។

### មតិកែលម្អរបស់ភាគីពាក់ព័ន្ធ

ភស្តុតាងនានា ដូចជា អង្កេត ការពិភាក្សាក្រុមគោលដៅ សម្ភាសន៍ អត្ថបទកាសែត សេចក្តីថ្លែងការណ៍ដៃគូ មតិកែលម្អ និងយន្តការដោះស្រាយបណ្តឹង ឬ ប្រភពដែលអាចមានដទៃទៀត បង្ហាញថា៖

- ប្រជាជន ទុកចិត្តលើអង្គការសង្គមស៊ីវិល និងជឿថាអង្គការមានគណនេយ្យភាពចំពោះស្នាដៃអនុវត្តការងារនិងកិច្ចប្រតិបត្តិការរបស់ខ្លួន។
- គណៈគ្រប់គ្រងជាន់ខ្ពស់ បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្ត ត្រូវបានមើលឃើញដោយភាគីពាក់ព័ន្ធទាំងអស់ ថាកំពុងធ្វើសកម្មភាពប្រកបដោយគណនេយ្យភាព។
- ភាគីពាក់ព័ន្ធ ទទួលស្គាល់ការសម្របតាម នវានុវត្តន៍ និងការកែលម្អកម្មវិធីរបស់អង្គការ ប្រកបដោយការទទួលខុសត្រូវ។

- ភាគីពាក់ព័ន្ធ បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តដឹងពីយន្តការដោះស្រាយវិវាទ និងបណ្តឹង និងជឿថាពួកគេត្រូវបានរក្សាការសម្ងាត់និងមានសុវត្ថិភាព។
- ភាគីពាក់ព័ន្ធ បុគ្គលិក និងអ្នកធ្វើការស្ម័គ្រចិត្តយល់ថាគណៈដឹកនាំឆ្លើយតបទៅនឹងបណ្តឹងនិងមតិកែលម្អរបស់ពួកគេ។

## សំណួរណែនាំសម្រាប់ការឆ្លុះបញ្ចាំង និងសកម្មភាព

- តើក្រុមប្រឹក្សាភិបាលរបស់អ្នកធ្វើដូចម្តេចដើម្បីធានាឱ្យបានប្រាកដនូវការប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវទ្រព្យសម្បត្តិអង្គការទាំងអស់ ការគោរពច្បាប់ជាធរមាននិងការប្រតិបត្តិប្រកបដោយសីលធម៌ និងការផ្តោតលើការសម្រេចចក្ខុវិស័យ និងបេសកកម្មនៃអង្គការរបស់អ្នកប្រកបដោយប្រសិទ្ធភាព?
- តើប្រជាជន បុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្ត សហការី ដៃគូ ម្ចាស់ជំនួយ និងរដ្ឋាភិបាល កំណត់ឱ្យគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់អ្នកមានគណនេយ្យភាពចំពោះគោលការណ៍អនុវត្តទាំងអស់ យ៉ាងដូចម្តេច?
- តើអ្នកគាំទ្រគណៈដឹកនាំប្រកបដោយការទទួលខុសត្រូវ ចក្ខុវិស័យ នវានុវត្តន៍ និងគណនេយ្យភាពនៅគ្រប់កម្រិតយ៉ាងដូចម្តេច?
- តើអ្នកស្នើសុំ វិភាគ និងឆ្លើយតបទៅនឹងមតិកែលម្អពីក្រុមភាគីពាក់ព័ន្ធសំខាន់ៗរបស់អ្នក រួមទាំងបុគ្គលិក យ៉ាងដូចម្តេច? តើការកែតម្រូវត្រូវបានសម្រេច និងបង្ហាញយ៉ាងដូចម្តេចនៅក្នុងអង្គការរបស់អ្នក?
- តើអ្នកលើកទឹកចិត្តយ៉ាងដូចម្តេចដល់មតិកែលម្អខាងក្នុង និងខាងក្រៅ និងធានាយ៉ាងដូចម្តេចឱ្យបានប្រាកដថាព័ត៌មានអំពីរបៀបដាក់បណ្តឹងប្រកបដោយសុវត្ថិភាព ត្រូវបានផ្សព្វផ្សាយជាសាធារណៈ?

# ពាក្យគន្លឹះ និងនិយមន័យ

**គណនេយ្យភាព:** ការផ្តោតជាសំខាន់លើការទទួលខុសត្រូវលើសកម្មភាព និងផលប៉ះពាល់, ឆ្លើយតប និងស្មោះត្រង់ចំពោះភាគីពាក់ព័ន្ធទាំងអស់ – ពោល គឺនិយោជិត សហគមន៍ ម្ចាស់ជំនួយ – តាមវិធីមួយដែលមានតម្លាភាព និងងាយយល់, ប្រឹងប្រែងបំផុតដើម្បីសម្រេចគោលបំណងបេសកកម្មតាមវិធីត្រឹមត្រូវនិងប្រកបដោយយុត្តិធម៌ និងចែករំលែកព័ត៌មានដោយបើកចំហរ។

**យុទ្ធនាការតស៊ូមតិ:** ការជំរុញជាសាធារណៈនូវរបៀបវារៈមួយទៅកាន់ពួកអ្នកគាំទ្រក្នុងគោលបំណងធ្វើឱ្យមានឥទ្ធិពលលើ ឬបង្កើតនូវការផ្លាស់ប្តូរ។

**ការសម្របតាម:** កែសម្រួលការប្រតិបត្តិឬបទដ្ឋានគណនេយ្យភាពរបស់អង្គការមួយ ដោយផ្អែកលើគោលការណ៍ ខ្លឹមសារ និងរចនាសម្ព័ន្ធនៃបទដ្ឋានសកលដោយធានាឱ្យបានប្រាកដថាការកែសម្រួលមានលក្ខណៈសមស្របនឹងបរិបទ និងសមត្ថភាពអង្គការ។

**លំហរពលរដ្ឋ:** ស្ថានភាពដែលអនុញ្ញាតឱ្យសង្គមស៊ីវិលនិងបុគ្គលិករៀបចំ ចូលរួម និងធ្វើការប្រាស្រ័យទាក់ទងដោយសេរី និងដោយគ្មានការរើសអើង ក្នុងគោលបំណង ជះឥទ្ធិពលលើរចនាសម្ព័ន្ធនយោបាយ និងសង្គមនៅជុំវិញពួកគេ (CIVICUS Monitor, 2016)។

**អង្គការសង្គមស៊ីវិល (CSO):** អង្គការពលរដ្ឋមិនរកចំណេញ និងមិនមែនរដ្ឋ ដែលនៅក្នុងនោះ ប្រជាជនចងក្រងខ្លួនឯង ដើម្បីផលប្រយោជន៍រួមនៅក្នុងវិស័យសាធារណៈ។ អង្គការសង្គមស៊ីវិល គ្របដណ្តប់លើអង្គការប្រភេទផ្សេងៗជាច្រើន រួមមានអង្គការសហគមន៍មូលដ្ឋាន អង្គការសមាជិកភាព អង្គការតស៊ូមតិ អង្គការផ្អែកលើបញ្ហា និងអង្គការផ្តល់សេវាកម្ម (Advisory Group on CSOs and Aid Effectiveness, 2008)។

**គំនិតផ្តួចផ្តើម គណនេយ្យភាពអង្គការសង្គមស៊ីវិល:** អង្គការសង្គមស៊ីវិល និងបណ្តាញ ដែលជះឥទ្ធិពល ជំរុញ និងដឹកនាំរបៀបវារៈនៃគណនេយ្យភាពអង្គការសង្គមស៊ីវិល នៅកម្រិតជាតិ តំបន់ ឬសកលលោក។ សកម្មភាពរបស់ពួកគេ រួមមានការផ្សព្វផ្សាយ និងការគ្រប់គ្រងក្រមសីលធម៌ ឬបទដ្ឋានគណនេយ្យភាពអង្គការសង្គមស៊ីវិល ក៏ដូចជា ការងារតស៊ូមតិ ការស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាព។ សកម្មភាពទាំងនេះ សំដៅកែលម្អការប្រតិបត្តិគណនេយ្យភាពរបស់អង្គការសង្គមស៊ីវិលទូទាំងពិភពលោក។

**បរិយាកាសអំណោយផល:** បរិស្ថានឬលំហរផ្ទៃក្រៅ ឬ បរិស្ថានប្រតិបត្តិការ ដែលរួមមានគោលនយោបាយរដ្ឋាភិបាល គោលនយោបាយផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ អាកប្បកិរិយាសហគមន៍ ក្តីរំពឹង និងនិយាមទាក់ទិននឹងអង្គការសង្គមស៊ីវិល។

**សមធម៌:** គុណភាពនៃការមានយុត្តិធម៌ មិនលម្អៀង និងការធានាឱ្យបានប្រាកដថាម្នាក់ៗមានលទ្ធភាពទទួលបានធនធាន កាលានុវត្តភាព អំណាច និងការទទួលខុសត្រូវ ដែលពួកគេត្រូវការ ដើម្បីឈាន ដល់សក្តានុពលប្រកបដោយសុខុមាលភាព (SGBA, Rising to the Challenge, 2009)។

**សមភាព:** ការប្រព្រឹត្តិចំពោះជនគ្រប់រូបដូចគ្នា ដោយមិនមានបុគ្គល ឬ ក្រុមបុគ្គលប្រព្រឹត្តិខុសគ្នា ឬ អនុគ្រោះតិចជាង ដោយផ្អែកលើមូលដ្ឋាននៃពូជសាសន៍ ភេទ ពិការភាព សាសនា ឬ ជំនឿ និន្នាការភេទ អាយុ ឬ ចរិតលក្ខណៈផ្សេងៗទៀតរបស់ពួកគេ (University of Edinburgh, Equality and Diversity, 2016)។

**យន្តការផ្តល់មតិកែលម្អ:** ប្រព័ន្ធផ្លូវការ និងការអនុវត្តនានា ដែលត្រូវបានបង្កើតឡើងដើម្បី ទទួលពិភាក្សា និងឆ្លើយតបទៅនឹងទស្សនៈរបស់ភាគីពាក់ព័ន្ធ អំពីស្នាដៃអនុវត្តការងារ និងផលប៉ះពាល់របស់អង្គការសង្គមស៊ីវិល។ បន្ទាប់មក ព័ត៌មាននេះត្រូវបានប្រើសម្រាប់គោលបំណងផ្សេងៗ រួមទាំងការធ្វើសកម្មភាពកែតម្រូវដើម្បីកែលម្អស្នាដៃអនុវត្តការងារ (ALNAP/ODI, Closing the Loop, 2014)។

**សុខុមាលភាពភពផែនដី:** បណ្តុំនៃប្រព័ន្ធអេកូឡូស៊ីប្រកបដោយតុល្យភាពល្អមួយ ដែលរួមចំណែកដល់សុខុមាលភាពសហគមន៍ និងសង្គម ដោយផ្តល់ទំនិញ និងសេវាកម្មនានា (រួមមានអាហារ ខ្យល់ស្អាត ទឹកស្អាត ឱសថ និងជីវភាពរស់នៅ) ដែលសំខាន់សម្រាប់ការរស់រានរបស់មនុស្ស សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ និងទ្រទ្រង់លទ្ធភាពរបស់ពួកគេក្នុងការស្រូបយក និងសះស្បើយពីការរំខាន (WHO, Discussion Paper, 2012)។

**សុខុមាលសង្គម:** សង្គមមួយដែលអនុញ្ញាតឱ្យសមាជិកទាំងអស់នៃសង្គមនោះ បំពេញតួនាទីមួយជាសមូហភាព និងជាបុគ្គល ក្នុងការកសាងអនាគតនៃសហគមន៍ពួកគេ និងក្នុងការបំពេញសេចក្តីត្រូវការរបស់ពលរដ្ឋខ្លួន។

**ផលប៉ះពាល់:** លទ្ធផលនិងឥទ្ធិពល (វិជ្ជមាន និងអវិជ្ជមាន) នៃគំនិតផ្តួចផ្តើម កម្មវិធី ឬ សកម្មភាពមួយ។

**យុត្តិធម៌:** ការធានាឱ្យបានប្រាកដថាប្រជាជនទាំងអស់មានសិទ្ធិស្មើគ្នា និងមានលទ្ធភាពទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយនៅក្នុងសង្គម ដោយគ្មានការរើសអើង។

**ការផ្លាស់ប្តូរវិជ្ជមានជាប់លាប់:** កិច្ចដំណើរការដែលនៅក្នុងនោះ សកម្មភាពរបស់អង្គការមួយ រួមចំណែកដល់ លទ្ធផលជាប់លាប់ដែលកែលម្អគុណភាពនៃជីវិតរបស់ប្រជាជន ក្នុងរយៈពេលវែង។

**គណៈអ្នកដឹកនាំ:** បុគ្គលិកកំពូលរបស់អង្គការ និងក្រុមប្រឹក្សាភិបាលរបស់អង្គការ អ្នកដែលផ្តល់ទិសដៅរួម និងការគ្រប់គ្រងនៃអង្គការ។

**ដៃគូ:** អង្គការ បុគ្គល និងភាគីដទៃទៀត ដែលយើងធ្វើការរួមជាមួយដែលមានតួនាទី និងការទទួលខុសត្រូវកំណត់ច្បាស់ ដើម្បីសម្រេចគោលបំណងរួម។

**ភាពជាដៃគូ:** កិច្ចព្រមព្រៀងមួយដើម្បីធ្វើសកម្មភាពដែលនឹងផ្តល់ប្រយោជន៍ ដល់អ្នកពាក់ព័ន្ធទាំងអស់ដោយនាំមកនូវលទ្ធផលដែលមិនអាចសម្រេចបានដោយអង្គការតែមួយដែលធ្វើប្រតិបត្តិការតែឯង និងដោយកាត់បន្ថយកិច្ចប្រឹងប្រែងត្រួតគ្នា។ ភាពជាដៃគូប្រកបដោយជោគជ័យបង្កើនផលប៉ះពាល់ និងប្រសិទ្ធភាពនៃសកម្មភាពមួយ តាមរយៈការប្រើធនធានរួមបញ្ចូលគ្នា និងកាន់តែមានប្រសិទ្ធផលជំរុញនវានុវត្តន៍ និងត្រូវសម្គាល់ដោយការតាំងចិត្តខ្ពស់ពីដៃគូនីមួយៗ (OECD, Successful Partnerships, 2006)។

**ប្រជាជន:** ក្រុមគោលដៅភាគច្រើនសម្រាប់ការងាររបស់អង្គការសង្គមស៊ីវិល ពោល គឺប្រជាជនដែលទទួលផលប្រយោជន៍ ដោយផ្ទាល់ពីការងាររបស់អង្គការ។ ប្រជាជនទាំងនេះ ក៏អាចសំដៅលើប្រជាជនដែលពាក់ព័ន្ធក្នុងការងាររបស់យើង រងផលប៉ះពាល់ពីការងាររបស់យើង ឬ ជនងាយរងគ្រោះ និងជួបការលំបាក។ អាស្រ័យលើប្រភេទការងារដែលអង្គការធ្វើ ជួនកាល ពួកគេត្រូវបានគេហៅថាជាអ្នកទទួលផល ឬ អតិថិជន។

**ប្រជាជនដែលធ្វើការជាមួយយើង:** ប្រជាជនទាំងនេះសំដៅលើបុគ្គលិក អ្នកធ្វើការស្ម័គ្រចិត្ត អ្នកពិគ្រោះការ ឬ ជនណាដែលធ្វើការងាររបស់អង្គការ ឬ តំណាងឱ្យអង្គការដោយផ្ទាល់។

**ទិន្នន័យផ្ទាល់ខ្លួន:** ព័ត៌មានណាដែលកំណត់អត្តសញ្ញាណ ឬ អាចត្រូវបានប្រើ ដោយផ្ទាល់ឬដោយប្រយោលដើម្បីកំណត់អត្តសញ្ញាណបុគ្គលមួយដោយ

ផ្អែកលើកត្តាមួយឬច្រើនដែលមានលក្ខណៈជាក់លាក់ទៅនឹងអត្តសញ្ញាណរូបវន្ត សរីរសាស្រ្ត ផ្លូវចិត្ត សេដ្ឋកិច្ច វប្បធម៌ ឬ សង្គមរបស់ជននោះ។

**សាធារណជនៈ** ក្រុមប្រជាជនដែលនៅក្រៅការងាររបស់អង្គការ និងដែលមិនទទួលផលប្រយោជន៍ដោយផ្ទាល់ពីការងាររបស់អង្គការ ប៉ុន្តែ មានចំណាប់អារម្មណ៍ខ្លះលើកិច្ចការដែលអង្គការធ្វើ ដោយសារការងារនោះកើតឡើងនៅក្នុងបរិស្ថានជីវិតរបស់ពួកគេ។ អ្នកទាំងនេះជួនកាលត្រូវបានគេហៅថាពលរដ្ឋ អ្នកស្រុក សង្គម។ល។

**បទដ្ឋានឯកសារយោងៈ** បទដ្ឋានមួយដែលអង្គការសង្គមស៊ីវិលមិនបានចូលរួមបង្កើត ឬ មិនត្រូវបានផ្ទៀងផ្ទាត់ជាមួយ ប៉ុន្តែ គឺជាបទដ្ឋានមួយដែលពួកគេអាចយោង នៅក្នុងការអភិវឌ្ឍការប្រតិបត្តិ និងការត្រួតពិនិត្យខ្លួនឯង។

**ធនធានៈ** ជំនួយជាហិរញ្ញវត្ថុឬមិនមែនជាហិរញ្ញវត្ថុដែលយើងទទួលពីសកម្មភាពកៀរគរមូលនិធិ ដៃគូផ្តល់មូលនិធិ អ្នកជួយឧបត្ថម្ភ សប្បុរសជន និងបុគ្គល ដែលយើងប្រើដើម្បីសម្រេចគោលបំណង និងគោលដៅទាំងឡាយនៃអង្គការរបស់យើង។

**មូលហេតុជាឫសគល់ៈ** មូលហេតុចម្បងនៅកម្រិតមូលដ្ឋានសម្រាប់ការកើតមាន និងភាពឋិតឋេរនៃបញ្ហាមួយ។ ជំនួសការផ្តោតលើឥទ្ធិពល និងរោគសញ្ញានៃបញ្ហាមួយ យើងត្រូវទទួលស្គាល់ និងដោះស្រាយមូលហេតុជាឫសគល់របស់វា ដើម្បីរួមចំណែកដល់ការផ្លាស់ប្តូរប្រកបដោយចីរភាព។

**បុគ្គលិកៈ** អ្នកទាំងនេះ គឺជាអ្នកដែលចូលរួមក្នុងការងាររបស់យើង ឬ ដែលធ្វើការជាមួយអង្គការ។ ពួកគេអាចត្រូវបានជួលជាផ្លូវការ ឬ តំណាងជាផ្លូវការ និងធ្វើសកម្មភាព ជួសមុខអង្គការនៅក្នុងការងាររបស់អង្គការ។ អ្នកទាំងនេះ រួមមានបុគ្គលិកទៀងទាត់ អ្នកធ្វើការស្ម័គ្រចិត្ត អ្នកពិគ្រោះការ និង ស្ថាប័នធ្វើសេចក្តីសម្រេចចិត្ត។

**ភាគីពាក់ព័ន្ធៈ** បុគ្គលនិងក្រុមទាំងឡាយដែលអាចប៉ះពាល់ឬត្រូវបានប៉ះពាល់ដោយគោលនយោបាយ និង/ឬ សកម្មភាពរបស់អង្គការ (Pathways to Accountability, the GAP Framework One World Trust, 2005)។

**បទដ្ឋាន** គោលការណ៍ និងនិយាមសម្រាប់វាស់គុណភាពនៃសេវា និងប្រព័ន្ធនានារបស់អង្គការ។

**សិទ្ធិរបស់ស្រ្តីនិងកុមារីៈ** សិទ្ធិរបស់ស្រ្តីនិងកុមារីគឺជាសិទ្ធិមនុស្សដែលត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៤៨។ សិទ្ធិទាំងនេះរួមមានជាអាទិ៍ សិទ្ធិរស់នៅដោយចាកផុតពីហិង្សាទាសភាព និងការរើសអើង សិទ្ធិទទួលបានការអប់រំ សិទ្ធិមានទ្រព្យសម្បត្តិ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានប្រាក់ឈ្នួលប្រកបដោយយុត្តិធម៌និងស្មើភាព។



csostandard.org

@CSOStandard

feedback@csostandard.org

បទដ្ឋានសកលសម្រាប់គណនេយ្យភាព អង្គការសង្គមស៊ីវិលត្រូវបានតាក់តែងដោយ៖

**Accountable Now,** International
**Australian Council for International Development,** Australia **Balkan Civil Society Development Network,** Balkans
**Cooperation Committee for Cambodia,** Cambodia
**InterAction,** USA
**Quality Assurance Certification Mechanism,** Uganda
**Rendir Cuentas,** Latin America and the Caribbean
**Voluntary Action Network India,** India
**Viwango,** Kenya
**International Civil Society Centre,** International

The term "Dynamic Accountability" was coined by Restless Development, a youth-led development agency.
More information via www.restlessdevelopment.org/dynamic-accountability

Sweden
Sverige

Developed with financial support from Sida,
the Swedish International Development Cooperation Agency.

# ១២ គោលការណ៍អនុវត្តដើម្បី មានគណនេយ្យភាពរឹងមាំ




**បទដ្ឋានសកល**
**សម្រាប់គណនេយ្យភាព**
**អង្គការសង្គមស៊ីវិល**